| ៨៣-លោក | មាន សានិត | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨៤-លោក | គង់ ប៊ុនគុគិ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨៥-លោក | ជា គីមឃាង | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨៦-លោក | រ៉ុម បូរីរ័ត្ន | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨៧-លោក | អ៊ិន ចាន់គង្គា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨៨-លោក | សាត ដាលាប | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៨៩-លោក | គង់ វិចិត្រ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩០-លោក | ជឹង វៃ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩១-លោក | វ សុខជា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩២-លោក | ហ៊ី ទិត្យម៉េង | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩៣-លោក | ហុក ផាន់ណា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩៤-លោក | សន សុផាត | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩៥-លោក | ម៉ឹង ច័ន្ទបញ្ញា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩៦-លោក | ឌុច វៃ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | |
|---|---|---|
| ៩៧-លោក | បាន វុទ្ធី | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩៨-លោក | ប៊ូ បាន | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ៩៩-លោកស្រី | ឌូ សុវណ្ណលីវ័ត្ន | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១០០-លោក | សន សិលករ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១០១-លោក | សៅ គឹមលាង | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១០២-លោក | ហេង សុជាវិទ្ធ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |
| ១០៣-លោកស្រី | និន ចិន្តា | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |

**-តាំងស៊ប់ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១**

| | | |
|---|---|---|
| ១០៤-លោក | វ៉ង រាជ | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤ |

**មាត្រា ២ :** តាំងស៊ប់លោក ប៉ូ **លីនដារា** ទៅក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៅក្រសួងសុខាភិបាល ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តមសីហមុនី

នស/រកត.០៤២១.៣០២៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ២០ *ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

ជូនចំពោះមុខ ព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ទូវ**

គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់៖

ក-គ្រឿងឥស្សរិយយស **ជាតូបការ** ៖

១-ឯកឧត្តម ម៉ៅ រិទ្ធីថា
២-ឯកឧត្តម ចាន់ សារុទ្ធ
៣-ឯកឧត្តម ហុង ណារិត

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ៖

១-ឯកឧត្តម ម៉ម អំណត់
២-ឯកឧត្តម គុយ ម៉ារិនឌី
៣-ឯកឧត្តម សាន វណ្ណទី

គ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ៖

ឯកឧត្តម រស់ សូដែន

នរោត្តម សីហមុនី

ពរសៈ ៤២០៤.៣៦៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយនេះជូនក្រោមព្រះរាជហត្ថលេខា ឬ បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/ ៣៦៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៨៥រូបៈ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១-លោក | សួន សុធឿន | ២-លោក | អ៊ុក ម៉ាការា |

ខ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | តាន់ ផាន់ណារ៉ា | ១៣-លោក | ទូ យុត្តិកា |
| ២-លោក | ស៊ិន សាន | ១៤-លោក | ប្រាក់ ណូម៉ា |
| ៣-លោក | ចាន់ វឌ្ឍនា | ១៥-លោក | ហាវ ផា |
| ៤-លោក | ងួន សុភាព | ១៦-លោក | ច័ន្ទ ប៊ុណ្ណិកា |
| ៥-លោក | ឡេង ទិត្យ | ១៧-លោក | ប៊ុន វ៉ាដា |
| ៦-លោក | ជី សុចិន្តា | ១៨-បណ្ឌិត | ឈួន ចំណាន |
| ៧-លោក | ម៉ក់ វិសាល់ | ១៩-លោកស្រី | ឌុច សុធារី |
| ៨-លោកស្រី | ផេង សុផាដា | ២០-លោកស្រី | ស៊ឹម ថាវរី |
| ៩-លោក | សួន ម៉ាលីន | ២១-លោកស្រី | ណយ ប៉ុក |
| ១០-លោក | សេង ស៊ុនហ្វ៊ត | ២២-លោក | ហួត សុធី |
| ១១-លោក | ចាន់ រិទ្ធី | ២៣-លោក | អ៊ុច សេងអាន |
| ១២-លោក | គ្រី វ៉ាវុធ | | |

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | គង់ វ៉ាញ | ២-លោក | ង៉ិន កុសល |

ឃ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា**

| | | | |
|---|---|---|---|
| ១-លោក | អួន សុវណ្ណ | ៥-លោក | ចាន់ រិទ្ធិ |
| ២-លោក | ឃុន កក្កដា | ៦-លោក | ប៉ា គីមអាង |
| ៣-លោក | ហ៊ិន សាផន | ៧-លោក | ហួន ហុង |
| ៤-លោកស្រី | ងិន ម៉ារ៉េន | ៨-លោកស្រី | ប៉ែន ណាវ៉ាន្នី |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | |
|---|---|---|---|
| ៩-លោក | គាម សុលិដា | ២៧-លោកស្រី | វង្ស សុបញ្ញា |
| ១០-លោក | ទូ វណ្ណៈ | ២៨-លោក | ហែម សាវ៉ាវុធ |
| ១១-លោក | តាន់ សារិទ្ធ | ២៩-លោក | បែន បុល្លីណា |
| ១២-លោក | យ៉ឹក សុខខេង | ៣០-លោក | អៀម ម៉ាយ៉ុងរី |
| ១៣-លោក | ពឹង ទ្រីដា | ៣១-លោកស្រី | ហ៊ឹង សុភារី |
| ១៤-លោក | ស្រ៊ុន បូរិទ្ធ | ៣២-លោក | សំរិត សំបូរ |
| ១៥-លោក | អ៊ុំង ជីប៉ោ | ៣៣-លោក | ងួន ម៉េង |
| ១៦-លោក | ឃឹម ឡុង | ៣៤-លោក | កៅ មុន្នីរិទ្ធ |
| ១៧-លោក | អ៊ុំង វឌ្ឍវិបុល | ៣៥-លោក | គុយ ហាក់ |
| ១៨-លោក | ឈក លក | ៣៦-លោក | កើត គា |
| ១៩-លោក | កែ វិជ្ជរ៉ា | ៣៧-លោកស្រី | ខៀវ សុជាតិ |
| ២០-លោក | លី គីមសែ | ៣៨-លោក | អ៊ូច ឡង់ |
| ២១-លោក | ឈិន សេងហួ | ៣៩-លោក | ហ៊ុម ប៊ុនថៃ |
| ២២-លោក | ម៉ៅ វណ្ណថន | ៤០-លោក | នេត ឈុនអ៊ាម |
| ២៣-លោក | គង់ វុធថា | ៤១-លោក | ថាត់ សុវណ្ណរិទ្ធ |
| ២៤-លោក | ហ៊ិន ធា | ៤២-លោកស្រី | ទុយ សុខខេង |
| ២៥-លោកស្រី | ចាន់ វន | ៤៣-លោក | ធីវ វណ្ណធីរ |
| ២៦-លោក | ហ៊ី សុផល | | |

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

| | | | |
|---|---|---|---|
| ១-លោក | ហុង ប៉ុណ្ណាកា | ៩-លោក | សុង ហុង |
| ២-លោក | សយ សុមេធា | ១០-លោក | ឈួន គីមឈោ |
| ៣-លោក | ហាស់ ពិសិទ្ធ | ១១-លោកស្រី | ព្រុំ បុណ្ណមី |
| ៤-លោក | ទូច ធា | ១២-លោក | ឌី ថារី |
| ៥-លោក | ចឹង បូរិន | ១៣-លោក | ប៊ុនទូនស៊ីម្មូណា |
| ៦-លោក | អ៊ុក សារ៉ាំ | ១៤-លោក | លឹម ងួនគ្រុយ |
| ៧-លោក | សំ សត្យា | ១៥-លោក | ផា ឋាម |
| ៨-លោកស្រី | កាំង ឃឹម | | |

ពរស.២១០៤.៣៦៩

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៦៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងមុខតំណែងឯកឧត្តម **ង៉ាហោង ជាឆុង** ជាអនុរដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរល.២១០៤.៣៧០

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/ ៣៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **កែម សារ៉ាត់** ជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា មានឋានៈស្មើ **អគ្គនាយក** ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានបង្គំថ្វាយព្រះមហាក្សត្រ ដើម្បីឡាយព្រះហស្តលេខា
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/ ៣៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ចាវ សោវលីង** (ZHAO SHAOLING) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៨៣ នៅខេត្តហ៊ូណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **អ៊ូ សៀវអ៊ី** (WU XIAOYI) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៨៤ នៅខេត្តហ៊្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២១០៤.៣៧៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ូ យុងឆាន** (SU YONGCAN) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៣ នៅខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរល.២១០៤.៣៧៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៧៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ចាង ឈឹង** (ZHANG CHENG) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៨៨ នៅខេត្តហ៊ូប៉ី សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៣៤.២១០៤.៣៧៧

នរោត្តមសីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/ ៣៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **អ៊ូ ម៉ោឈាំង** (WU MAOLIANG) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៨៨ នៅខេត្តហ្វ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៩៧.៥២០៤.៣៧៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២១*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងមុខតំណែងឯកឧត្តម **ប៉ុល សុធា** ជាអនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ២:** តែងតាំងមុខតំណែង និងផ្តល់ឋានៈ ឯកឧត្តម **ហ៊ីម អូន** ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តមសីហមុនី

៧៖៣.២១០៤.៣៤០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០៤២១/៣៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ដល់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥ រូប :

១- ឯកឧត្តម **ជា ទុធណា** ជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម **អ៊ុំ សិទ្ធីរ៉ា** ជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម **ឆាយ រតនៈ** ជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការនៃអគ្គាធិការដ្ឋាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម **ឡុញ ធីណា** ជា ទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយក

៥- ឯកឧត្តម **សូ សុទ្ធី** ជា ទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

៧១៩. ២១០៤. ៣៨១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤០.អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៣ ៨៩៧ ៩០០ ០០០ រៀល (ដប់បីប៊ីលានប្រាំបីរយកៅសិបប្រាំពីរលានប្រាំបួនរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ចំណាយរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ១៣។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៤ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១.-**

ផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៤ ចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ចំនួន ៥០ ០០០ (ប្រាំម៉ឺន)រៀលក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីនគរបាលជាតិកម្ពុជា មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ មន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រីខុទ្ទកាល័យដូចមានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដែលជាប្រធានស្ថាប័ន ទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីនៃការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតដែលកំពុងបម្រើការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ និងជនពិការដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ និងអតីតមន្ត្រីនគរបាលជាតិកម្ពុជា។ ចំពោះគ្រួសារជនពលីនិងគ្រួសារជនមរណៈ ជាអតីតយុទ្ធជន ត្រូវបានផ្តល់ជូនប្រាក់ឧបត្ថម្ភនេះ ចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល ក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងចំនួន ៥០ ០០០(ប្រាំម៉ឺន)រៀល ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ក្នុងមួយគ្រួសារ។

ប្រាក់ឧបត្ថម្ភនេះត្រូវបានផ្តល់សម្រាប់ម្នាក់ៗ ឬមួយគ្រួសារតែមួយកន្លែងនិងមួយលើកប៉ុណ្ណោះ។

**មាត្រា២ ._**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភខាងលើ ត្រូវអនុវត្តឱ្យបានមុនថ្ងៃចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៤ និងពិធីបុណ្យភ្ជុំបិណ្ឌ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ដោយត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

១. ការបើកផ្តល់ប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តតាមគណនីបៀវត្សរបស់សាមីជន ឬគ្រួសារជនពលីនិងគ្រួសារជនមរណៈ ជាអតីតយុទ្ធជន។

២. ក្រសួង ស្ថាប័ន និងអង្គភាពដែលមិនទាន់បានបើកគណនីបៀវត្សសម្រាប់មន្ត្រីរាជការ បុគ្គលិក និងភ្នាក់ងារសាធារណៈរបស់ខ្លួន ត្រូវចាត់ចែងការបើកផ្តល់ប្រាក់ឧបត្ថម្ភឱ្យបានដល់សាមីជនម្នាក់ៗគ្រប់ចំនួននិងទាន់ពេលវេលា។

៣. និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល អតីតយោធិននៃកងយោធពលខេមរភូមិន្ទ និងអតីតមន្ត្រីនគរបាលជាតិកម្ពុជាដែលកំពុងបំពេញការងារជាមន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ ឬមុខតំណែងផ្សេងទៀតដែលមានបញ្ជាក់ក្នុងអនុក្រឹត្យនេះ ត្រូវទទួលប្រាក់ឧបត្ថម្ភតែមួយកន្លែងដែលចាត់ចែងបើកផ្តល់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៤. ក្រសួង ស្ថាប័ន ត្រូវទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់ រៀបចំសំណើ និងធ្វើការបើកផ្តល់ប្រាក់ឧបត្ថម្ភដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ដោយមិនរាប់បញ្ចូលមុខសញ្ញានិវត្តជនក្នុងចំណុច៣ខាងលើ។

**មាត្រា៣ ._**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី ត្រូវសហការនិងចាត់ចែងរៀបចំការបើកផ្តល់ជាបុរេប្រទានសម្រាប់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីឱ្យដល់សាមីជនម្នាក់ៗយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ និងប្រាក់ឧបត្ថម្ភក្នុងឱកាសបុណ្យភ្ជុំបិណ្ឌឱ្យដល់សាមីជនម្នាក់ៗ នៅក្នុងពេលបើកបៀវត្សនៃខែតុលា ឆ្នាំ២០២១ មុនពិធីបុណ្យភ្ជុំបិណ្ឌ។

ក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវលើកសំណើដាក់ស្តែងអំពីចំនួនមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាការប្រញាប់ ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំប្រកាសបន្ថែមឥណទានថវិកាជូនទាន់ពេលវេលានិងធានាឱ្យការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះអនុវត្តបានទាន់ពេលវេលា។

**មាត្រា៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

រដ្ឋមន្ត្រី
**ក្រសួងមុខងារសាធារណៈ**

**ព្រុំ សុខា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/១៤៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- លិខិតលេខ ១១១៨/១៩ ល.ស ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

## សម្រេច

**មាត្រា ១.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដី ០១កន្លែង មានចំនួន ០៤ (បួន)ល្វែង ទំហំ ៣២០ (បីរយម្ភៃ)ម៉ែត្រការ៉េ និងអគារចំនួន ០៤ (បួន)ល្វែង ($E_0+E_1$) មានទំហំ ៦៤០ (ប្រាំមួយរយសែសិប)ម៉ែត្រការ៉េ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជូនក្រុមគ្រួសារមន្ត្រីរាជការចំនួន ០៤ (បួន) គ្រួសារ ស្ថិតនៅប្លុកអក្សរ(U) ភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានបង្ហាញក្នុងគំនូសប្លង់បង្ហាញទីតាំងដី និងអគារ ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ផ្ទៃដីដែលបានធ្វើអនុបយោគដូចមានកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់នីតិវិធីបន្តដោយក្រសួងផែនការ ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រង ព្រមទាំងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនក្រុមគ្រួសារមន្ត្រីរាជការ ឱ្យទទួលបានកម្មសិទ្ធិស្របច្បាប់ស្របតាមនីតិវិធីប្រទានកម្មជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង-ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## គំនូសបង្ហាញទីតាំងដី និង អគារ ០៤ល្វែង

របស់មន្ទីរផែនការខេត្ត ដែលត្រូវកាត់ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ប្រគល់ជូនក្រុមគ្រួសារមន្ត្រីរាជការ ចំនួន ០៤ គ្រួសារ ស្ថិតនៅប្លុកអក្សរអ៊ុយ នៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

យោង : - លិខិតស្នើសុំលេខ: ០៤០/១៩ ផកខ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៩ របស់មន្ទីរផែនការខេត្ត ។




**កំណត់សំគាល់**

- ក្បាលដី និង អគារ ស្នើសុំកាត់ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ ចំនួន ០៤ល្វែង
- \+ ដី ០៤ល្វែង ទំហំ : 16m x 20m = 320m²
- \+ អគារចំនួន ០៤ល្វែង ០១ជាន់ ( $E_0 + E_1$ ) ទំហំ (4m x 20m) x 4 = 640m²

(ក) ឈ្មោះ រស់ សុផន កាន់កាប់ដី ១ល្វែង ទំហំ = 4m x 20m = 80m²
អគារចំនួន ០១ល្វែង ( $E_0 + E_1$ ) ទំហំ (4m x 20m)x2 =160m²

(ខ) ឈ្មោះ សោម សុខេន កាន់កាប់ដី ១ល្វែង ទំហំ= 4m x 20m = 80m²
អគារចំនួន ០១ល្វែង ( $E_0 + E_1$ ) ទំហំ (4m x 20m)x2 =160m²

(គ) ឈ្មោះ ព្រំ ស៊ីណា កាន់កាប់ដី ១ល្វែង ទំហំ = 4m x 20m = 80m²
អគារចំនួន ០១ល្វែង ( $E_0 + E_1$ ) ទំហំ (4m x 20m)x2 =160m²

(ឃ) ឈ្មោះ ទុន សុខលីម កាន់កាប់ដី ១ល្វែង ទំហំ = 4m x 20m = 80m²
អគារចំនួន ០១ល្វែង ( $E_0 + E_1$ ) ទំហំ (4m x 20m)x2 =160m²

ផ្លូវ

ថ្ងៃ អង្គារ ០៤កើត ខែ ពិសាខ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
បន្ទាយមានជ័យ ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៩
អ្នកចង្អុលបង្ហាញ
តំណាងដោយមន្ទីរផែនការខេត្ត

ព្រំ ស៊ីណា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ



ស៊ា

- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៦ ស្តីពីវិសោធនកម្មមាត្រា៧ និងមាត្រា២០ នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តម **ខូច មករា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| ២.ឯកឧត្តម **វង្សៀន ស៊ុនលី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣.ឯកឧត្តម **ជា មានិត** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៤.ឯកឧត្តម **ជាប សត្ថារតន៍** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៥.ឯកឧត្តម **យ៉ិនឡៀង ពុទ្ធិរ៉ា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៦.ឯកឧត្តម **គង់ ផល្លៈ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៧.ឯកឧត្តម **ញ៉ឹក កោសល្យវិទ្យា** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៨.ឯកឧត្តម **តុល ញ៉ាំអ៉** | អគ្គនាយកនៃអគ្គនាយកដ្ឋានទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ៩.លោក **ម៉ែន ឧត្តា** | ប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

**មាត្រា២ .-**

គណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការងារបច្ចេកទេសនិងឧបករណ៍ទូរគមនាគមន៍ទាំងអស់របស់ទូរគមនាគមន៍កម្ពុជា
- ដឹកនាំ គ្រប់គ្រង និងចាត់ចែងការងារទូទៅនិងហិរញ្ញវត្ថុនៃទូរគមនាគមន៍កម្ពុជា និងអង្គភាពប្រតិបត្តិនៃទូរគមនាគមន៍កម្ពុជា
- រក្សាស្ថិរភាពនៃទូរគមនាគមន៍កម្ពុជា ដើម្បីបញ្ចៀសការខាតបង់អាជីវកម្ម
- វាយតម្លៃទ្រព្យសម្បត្តិ និងស្ថានភាពអាជីវកម្មទាំងអស់របស់ទូរគមនាគមន៍កម្ពុជា
- វាយតម្លៃពីសមត្ថភាពនិងរៀបចំផែនការនិយោជិត បុគ្គលិករបស់ទូរគមនាគមន៍កម្ពុជាជាជំហានៗ
- ដោះស្រាយគោលនយោបាយដល់និយោជិត បុគ្គលិករបស់ទូរគមនាគមន៍កម្ពុជាដែលត្រូវរំសាយ
- ដោះស្រាយបញ្ហាផ្សេងទៀតដែលអាចកើតមានជាយថាហេតុ

- ពិនិត្យ និងរៀបចំឡើងវិញលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រតិបត្តិការរបស់ទូរគមនាគមន៍កម្ពុជា
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈក្រសួងអាណាព្យាបាលទាំងពីរ
- បំពេញភារកិច្ចផ្សេងៗទៀតដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៣ .-**

គណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជាមានតំណាងអង្គភាពប្រឆាំងអំពើពុករលួយចូលរួមជាអ្នកសង្កេតការណ៍ ដូចមានរាយនាមខាងក្រោម៖

១.ឯកឧត្តម **សុត ឆា** អគ្គនាយកនៃអគ្គនាយកដ្ឋានប្រតិបត្តិការ នៃអង្គភាពប្រឆាំងអំពើពុករលួយ

២.លោកស្រី **អ៊ូ ស៊ីថា** ប្រធាននាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់ នៃអង្គភាពប្រឆាំងអំពើពុករលួយ។

**មាត្រា៤ .-**

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា មិនត្រូវមានសម្ព័ន្ធភាពជាមួយក្រុមហ៊ុនឯកជនណាមួយដែលអាចនឹងធ្វើឱ្យមានទំនាស់ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសជាមួយទូរគមនាគមន៍កម្ពុជា។

**មាត្រា៥ .-**

អនុប្រធាន សមាជិក និងអ្នកសង្កេតការណ៍នៃគណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួសបាន។

**មាត្រា៦ .-**

គណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា អាចបង្កើតក្រុមការងារហិរញ្ញវត្ថុ ក្រុមការងារបច្ចេកទេស ជាសេនាធិការរបស់គណៈកម្មការចំពោះកិច្ច និងដោះស្រាយគោលនយោបាយជូននិយោជិត បុគ្គលិកនៃទូរគមនាគមន៍កម្ពុជា ដែលត្រូវបង្កើតដោយសេចក្តីសម្រេចរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា អាចស្នើសុំចាត់តាំងអ្នកគ្រប់គ្រងបណ្តោះអាសន្ន ១រូប ដែលមានសមត្ថភាព ជំនាញ និងបទពិសោធន៍ខ្ពស់ ដោយសេចក្តីសម្រេចរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីដឹកនាំការងារប្រចាំថ្ងៃរបស់ទូរគមនាគមន៍កម្ពុជា តាមការណែនាំនិងតម្រង់ទិសរបស់គណៈកម្មការចំពោះកិច្ច។

**មាត្រា៧ .-**

គណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា មានសិទ្ធិស្នើសុំកិច្ចសហការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត។

គណៈកម្មការចំពោះកិច្ចដើម្បីធ្វើកំណែទម្រង់ទូរគមនាគមន៍កម្ពុជា មានសិទ្ធិប្រើត្រារបស់ទូរគមនាគមន៍កម្ពុជា ក្នុងការបំពេញតួនាទីនិងភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា" សរសេរជាអក្សរកាត់ថា "ស.ប.វ.ក" និងជាភាសាអង់គ្លេសថា "Cambodia University of Technology and Science" សរសេរជាអក្សរកាត់ថា "CamTECH" ។

**មាត្រា២.-**

ស.ប.វ.ក មានទីតាំងស្ថិតនៅតំបន់អភិវឌ្ឍន៍ជ្រោយចង្វារ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣.-**

ស.ប.វ.ក ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ដែលមានមហាវិទ្យាល័យចំនួន៥ ដូចខាងក្រោម៖

១. មហាវិទ្យាល័យវិស្វកម្ម មាន៤ដេប៉ាតឺម៉ង់៖

១.១. ដេប៉ាតឺម៉ង់វិស្វកម្មរ៉ូបូតនិងស្វ័យប្រវត្តិកម្ម
- មុខជំនាញ វិស្វកម្មរ៉ូបូតនិងស្វ័យប្រវត្តិកម្ម

១.២. ដេប៉ាតឺម៉ង់វិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិក
- មុខជំនាញ វិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិក
- មុខជំនាញ វិស្វកម្មប្រព័ន្ធត្រួតពិនិត្យ
- មុខជំនាញ វិស្វកម្មថាមពល
- មុខជំនាញ វិស្វកម្មអេឡិចត្រូនិកនិងទូរគមនាគមន៍

១.៣. ដេប៉ាតឺម៉ង់វិស្វកម្មមេកានិក
- មុខជំនាញ វិស្វកម្មមេកាត្រូនិក
- មុខជំនាញ វិស្វកម្មយានយន្ត
- មុខជំនាញ វិស្វកម្មគ្រឿងម៉ាស៊ីន
- មុខជំនាញ វិស្វកម្មអវកាស

១.៤. ដេប៉ាតឺម៉ង់វិស្វកម្មឧស្សាហកម្ម
- មុខជំនាញ វិស្វកម្មឧស្សាហកម្ម

២. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មាន៦ដេប៉ាតឺម៉ង់៖

២.១. ដេប៉ាតឺម៉ង់ច្នៃម៉ូត
- មុខជំនាញ ការច្នៃម៉ូតផលិតផល

២.២. ដេប៉ាតឺម៉ង់ភាសាអង់គ្លេស
- មុខជំនាញ បង្រៀនភាសាអង់គ្លេស
- មុខជំនាញ បកប្រែភាសាអង់គ្លេស
- មុខជំនាញ ភាសាអង់គ្លេសសម្រាប់ធុរកិច្ចនិងពាណិជ្ជកម្ម

- មុខជំនាញ ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈ

២.៣. ដេប៉ាតឺម៉ង់ចិន

- មុខជំនាញ បង្រៀនភាសាចិន
- មុខជំនាញ បកប្រែភាសាចិន
- មុខជំនាញ ភាសាចិនសម្រាប់ធុរកិច្ច
- មុខជំនាញ ភាសាចិនសម្រាប់បដិសណ្ឋារកិច្ច
- មុខជំនាញ ភាសាចិនសម្រាប់ទំនាក់ទំនងវិជ្ជាជីវៈ

២.៤. ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងបច្ចេកវិទ្យាទំនាក់ទំនង

- មុខជំនាញ ប្រព័ន្ធផ្សព្វផ្សាយនិងបច្ចេកវិទ្យាទំនាក់ទំនង
- មុខជំនាញ វិទ្យាសាស្ត្រទំនាក់ទំនង
- មុខជំនាញ ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយនិងព័ត៌មាន
- មុខជំនាញ បច្ចេកវិទ្យាឌីជីថលនិងការគ្រប់គ្រង

២.៥. ដេប៉ាតឺម៉ង់វប្បធម៌និងវិទ្យាសាស្ត្រសង្គម

- មុខជំនាញ ប្រវត្តិសាស្ត្រនិងវប្បធម៌
- មុខជំនាញ វិទ្យាសាស្ត្រសង្គម

២.៦. ដេប៉ាតឺម៉ង់អប់រំ

- មុខជំនាញ ការអប់រំកុមារតូច
- មុខជំនាញ ការអប់រំនិងការបណ្តុះបណ្តាល
- មុខជំនាញ បច្ចេកវិទ្យាអប់រំ
- មុខជំនាញ ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងការអប់រំ

៣. មហាវិទ្យាល័យធុរកិច្ចនិងគ្រប់គ្រង មាន៥ដេប៉ាតឺម៉ង់៖

៣.១. ដេប៉ាតឺម៉ង់គ្រប់គ្រងសំណង់

- មុខជំនាញ ការគ្រប់គ្រងសំណង់

៣.២. ដេប៉ាតឺម៉ង់គ្រប់គ្រងការដឹកជញ្ជូននិងភស្តុភារកម្ម

- មុខជំនាញ គ្រប់គ្រងការដឹកជញ្ជូន
- មុខជំនាញ គ្រប់គ្រងភស្តុភារកម្ម

៣.៣. ដេប៉ាតឺម៉ង់គ្រប់គ្រងផលិតកម្ម

- មុខជំនាញ ការគ្រប់គ្រងផលិតកម្ម
- មុខជំនាញ ការគ្រប់គ្រងចង្វាក់ផលិតកម្ម

៣.៤. ដេប៉ាតឺម៉ង់គ្រប់គ្រងកីឡានិងការកំសាន្ត

- មុខជំនាញ គ្រប់គ្រងកីឡានិងការកំសាន្ត

៣.៥. ដេប៉ាតឺម៉ង់អាជីវកម្មនិងការគ្រប់គ្រង

- មុខជំនាញ ការគ្រប់គ្រងសហគ្រាសធុនតូចនិងមធ្យម ដោយមានការនវានុវត្តន៍និងសហគ្រិនភាព

- មុខជំនាញ ការគ្រប់គ្រងហានិភ័យនិងបញ្ញាធុរកិច្ច

៤. មហាវិទ្យាល័យវិទ្យាសាស្ត្រអនុវត្តន៍ មាន៣ដេប៉ាតឺម៉ង់៖

៤.១. ដេប៉ាតឺម៉ង់គណិតវិទ្យាឧស្សាហកម្មនិងអនុវត្តន៍

- មុខជំនាញ គណិតវិទ្យាឧស្សាហកម្មនិងអនុវត្តន៍

៤.២. ដេប៉ាតឺម៉ង់ស្ថិតិអនុវត្តន៍

- មុខជំនាញ ស្ថិតិអនុវត្តន៍

៤.៣. ដេប៉ាតឺម៉ង់ហិរញ្ញវត្ថុកុំព្យូទ័រនិងការគ្រប់គ្រងហានិភ័យ

- មុខជំនាញ ហិរញ្ញវត្ថុកុំព្យូទ័រនិងការគ្រប់គ្រងហានិភ័យ

៥. មហាវិទ្យាល័យបរិស្ថានសំណង់ប្រកបដោយចីរភាព មាន៤ដេប៉ាតឺម៉ង់៖

៥.១. ដេប៉ាតឺម៉ង់ស្ថាបត្យកម្មនិងការរចនាផ្ទៃកខាងក្នុង

- មុខជំនាញ ស្ថាបត្យកម្ម
- មុខជំនាញ ការរចនាផ្ទៃកខាងក្នុង

៥.២. ដេប៉ាតឺម៉ង់ផែនការទីក្រុងនិងតំបន់

- មុខជំនាញ ផែនការទីក្រុងនិងតំបន់

៥.៣. ដេប៉ាតឺម៉ង់អចលនទ្រព្យ

- មុខជំនាញ ការគ្រប់គ្រងអចលនទ្រព្យ
- មុខជំនាញ រដ្ឋបាលនិងការគ្រប់គ្រងដីធ្លី

៥.៤. ដេប៉ាតឺម៉ង់ការគ្រប់គ្រងថាមពលឧស្សាហកម្ម

- មុខជំនាញ ការគ្រប់គ្រងថាមពលឧស្សាហកម្ម

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី រៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យ សុំប្តូរឈ្មោះថ្មី ទីតាំងថ្មី ឬពង្រីកទីតាំងថ្មី ដោយរៀបចំសំណុំបែបបទស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤.-**

**ស.ប.ទ.ភ** ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ប.ទ.ភ** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥.-**

សាកលវិទ្យាធិការនៃ **ស.ប.ទ.ភ** មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង **ស.ប.ទ.ភ** និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំបង្កើតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិនមុននឹងជ្រើសរើសនិស្សិតចូលរៀនឆ្នាំទីមួយ កម្រិតបរិញ្ញាបត្រ

- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរពនិងអនុវត្តតាមបទដ្ឋាន និងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៦.-**

និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សា និងបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ **ស.ប.វ.ក** ផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៩ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៤៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៥ ៨៨៦ ៦០០ ០០០ រៀល (ដប់ប្រាំបីលានប្រាំបីរយប៉ែតសិបប្រាំមួយលានប្រាំមួយរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដោះស្រាយតម្រូវការចំណាយការងាររបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០២១។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩ កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧០ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងនិយ័តកម្មប្តូរប្រភេទក្របខណ្ឌជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ :** និយ័តកម្មប្តូរប្រភេទក្របខណ្ឌជូនលោក **កែវ រតនៈបញ្ញា** ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ១០ នៃក្របខណ្ឌលេខាធិការរដ្ឋបាល មកជាឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៤ នៃក្របខណ្ឌមន្ត្រីក្រមការ ក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥១៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-** តែងតាំងមន្ត្រីរាជការចំនួន ៣ រូប ជាអគ្គាធិការរង និងប្រធាននាយកដ្ឋាន នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម :

១- លោកស្រី **ឌិន រម្មនា** ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋាន

២- លោកស្រី **ម៉ៅ ពុទ្ធី** ជាប្រធាននាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី ២ នៃអគ្គាធិការដ្ឋាន

៣- លោក **មាស ទណ្ឌថា** ជាប្រធាននាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី ៣ នៃអគ្គាធិការដ្ឋាន ។

**មាត្រា ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន មានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១.-** សម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប នៃក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ៖

១- លោក **ហុង តារ៉ាវុធ** សម្រួលភារកិច្ចពីប្រធាននាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប មកជាប្រធាននាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

២- លោក **គង់ គីមស្រេង** សម្រួលភារកិច្ចពីបច្ចុប្បន្នប្រធាននាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងត្បូងបឹងទន្លេសាប មកជាប្រធាននាយកដ្ឋានអភិរក្សតំបន់ការពារធម្មជាតិដីគោកខាងជើងបឹងទន្លេសាប នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

៣- លោក **ហេង ហុង** ជាប្រធាននាយកដ្ឋានតំបន់បេតិកភណ្ឌ នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជំនួសលោក **លឿង កេសរោ** ដែលត្រូវទទួលភារកិច្ចថ្មី។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*អន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ១១ រូប ជាប្រធាននាយកដ្ឋាន នៃបេឡាជាតិសន្តិសុខសង្គម របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម ៖

១-លោក **កែវ ប៊ុនណា** ជាប្រធាននាយកដ្ឋានអធិការកិច្ចសន្តិសុខសង្គម

២-លោកស្រី **សុខ សូលីណា** ជាប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រងធនធានមនុស្ស

៣-លោកស្រី **ម៉េត សុគន្ធឡាលីន** ជាប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និង គណនេយ្យ

៤-លោក **ជី សួរ** ជាប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

៥-លោក **លៀង ពន្លក** ជាប្រធាននាយកដ្ឋានគោលនយោបាយសន្តិសុខសង្គម

៦-លោក **ហេង សុផាន់ណារិទ្ធ** ជាប្រធាននាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណៈ

៧-លោក **ហុង សុខហៀប** ជាប្រធាននាយកដ្ឋានបញ្ជិកា និងភាគទាន

៨-លោក **ឧត ម៉ុឡារី** ជាប្រធាននាយកដ្ឋានសេវាមូលដ្ឋានសុខាភិបាល

៩-លោក **គាត ពុធណារិទ្ធិ** ជាប្រធាននាយកដ្ឋានគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម

១០-លោក **ជៀក លីម៉េង** ជាប្រធាននាយកដ្ឋានស្តារនីតិសម្បទា

១១-លោក **សុក ម៉ូរ៉ា** ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ២២២២ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១ .-** តែងតាំងលោក **ចាន់ ដារុធ** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសលោក **ចេវ សុខេង** ដែលបានចូលនិវត្តន៍។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ២២៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងលោកស្រី **ឆាយ ច័ន្ទនីរ៉ា** ជាប្រធាននាយកដ្ឋានសរុប និងព័ត៌មាន នៃអគ្គនាយកដ្ឋានទឹកស្អាតរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជំនួសលោក ប៊ុន ចាន់គង់ ដែលបានផ្ទេរទៅទទួលភារកិច្ចថ្មី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៧៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ខិន ខិនដា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាលរង នៃគណៈអភិបាលខេត្តកែប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦០៦៤. អនក្រ.តត-៩ ៩

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោកស្រី **ឌិត សុខា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ជាអភិបាល នៃគណៈអភិបាលក្រុងកែប ខេត្តកែប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ .-**

ត្រូវបានបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ជាបណ្ដោះអាសន្នសម្រាប់រយៈពេល ១៤ថ្ងៃ គិតចាប់ពីវេលាម៉ោងសូន្យនាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ក្នុងគោលបំណងធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល និងទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ត្រូវចាត់ទុកជាភូមិសាស្ត្រតែមួយដែលត្រូវបានបិទខ្ទប់។

**ប្រការ២ .-**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នេះ បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ប្រសិនបើគ្មានការចាំបាច់។

ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្មក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដែលមិនមានការហាមឃាត់ដូចបានកំណត់ក្នុងប្រការ៣ និងដោយមានភ្ជាប់ឯកសារបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម ដែលចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ ឬអាជ្ញាធរដែនដីដែលមានទីតាំងនៅជិតបំផុត
- ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដែលអនុញ្ញាតឱ្យបើកដំណើរការដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើដំណើរក្នុងគោលបំណងនេះ អាចធ្វើឡើងដោយសមាជិកយ៉ាងច្រើន ២ (ពីរ) នាក់ ក្នុងមួយលំនៅឋានឬទីសំណាក់ មិនឱ្យលើសពី ៣(បី) ដង ក្នុងមួយសប្ដាហ៍ និងនៅទីតាំងដែលជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រក្រុង ឬខណ្ឌដែលខ្លួនរស់នៅ ដោយត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួន
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់ នៅក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់នេះ ចេញក្រៅឬចូលក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីអាជ្ញាធរដែលអនុវត្តវិធានការបិទខ្ទប់ ដោយកំណត់ចំនួនមនុស្សមិនឱ្យលើសពី ៤ (បួន) នាក់សម្រាប់ករណីនីមួយៗ ប៉ុន្តែត្រូវអនុវត្តដាច់ខាតនូវកាតព្វកិច្ចទាក់ទងនឹងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមកាលកំណត់ និងនៅក្នុង ឬចេញក្រៅរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរសាធារណៈ

- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រភូមិដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំមនុស្សលើសពី ២ (ពីរ) នាក់
- ការធ្វើដំណើររបស់មន្ត្រីការទូត មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការហិរញ្ញវត្ថុអន្តរជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ
- ការធ្វើដំណើររបស់អ្នកសារព័ត៌មាន ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ
- ការធ្វើដំណើរចេញ-ចូលតំបន់បិទខ្ទប់តាមផ្លូវអាកាស ដោយត្រូវគោរពតាមបទប្បញ្ញត្តិ និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាលជាធរមាន និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។

រាល់ការលើកលែងខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៣ ..**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវបានហាមឃាត់រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។

ប៉ុន្តែ សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ និងកងកម្លាំងប្រដាប់អាវុធ ប៉ុន្តែប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមា ដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។ ប្រធានស្ថាប័នអាចសម្រេចផ្អាកការងារដែលមិនចាំបាច់ជាបណ្ដោះអាសន្ន តាមការជាក់ស្ដែង
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារ និងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីសត្តឃាត ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ
- សកម្មភាពការងារដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ តាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាពន្លត់អគ្គិភ័យ, សេវាផ្គត់ផ្គង់អគ្គិសនី, ទឹកស្អាត, សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង ជាដើម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- ការផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ ផ្សារលក់ដុំ ផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្ដាប់ធ្នាប់ ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់, ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស ឬទីតាំងផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- ការផ្គត់ផ្គង់សេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ សេវាសង្គ្រោះបន្ទាន់, សេវាសុខាភិបាល និងឱសថស្ថាន, សេវាប្រៃសណីយ៍-ទូរគមនាគមន៍, សេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាដែលជា

តម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមា

- សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់
- សេវាកម្មដឹកជញ្ជូនទំនិញចាំបាច់ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់
- សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ចនៃប្រទេស និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៤ ..**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវហាមឃាត់រាល់ការជួបជុំ ឬការប្រមូលផ្ដុំមនុស្ស។ ប៉ុន្តែ ការជួបជុំ ឬការប្រមូលផ្ដុំមនុស្ស អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្ដុំមនុស្ស និងការជួបជុំរបស់បុគ្គលិកសុខាភិបាល ដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកមកវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងការជួបជុំរបស់បុគ្គលិកសុខាភិបាលដែលបំពេញការងារសង្គ្រោះបន្ទាន់ផ្សេងទៀត និង
- ការជួបជុំរបស់អាជ្ញាធរមានសមត្ថកិច្ច កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ក្នុងការបំពេញការងារថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។

រាល់ការជួបជុំ ឬការប្រមូលផ្ដុំមនុស្សដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចកិច្ចត្រូវអនុវត្តនូវវិធានការសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើកលែងតែចំពោះការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា។

**ប្រការ៥ ..**

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងប្រការ២ នៃសេចក្ដីសម្រេចនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ, ការដឹកជញ្ជូនទំនិញ, ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ, ការធ្វើដំណើរទៅនិងមកពីទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឱ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យនៅបើកដំណើរការស្របតាមប្រការ៣ នៃសេចក្តីសម្រេចនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ សេវាសណ្ឋាគារ និងផ្ទះសំណាក់ និងសេវាសាធារណៈចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរ មានសមត្ថកិច្ច។

ការធ្វើដំណើរចេញ-ចូលឆ្លងកាត់ព្រំប្រទល់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្តល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ សេវាពាក់ព័ន្ធនឹងការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ឬសេវាដឹកជញ្ជូនទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៦ .-**

ត្រូវបានបង្កើតគណៈកម្មការជាតិគ្រប់គ្រងនិងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ សរសេរជាអក្សរកាត់ថា "**គ.ប.ខ.**" ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ | អនុប្រធាន |
| ៥-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦-ឯកឧត្តម **ឃួង ស្រេង** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧-ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨-ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម **អ៊ុច បូរិទ្ធ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១២-ឯកឧត្តម **ស្វាយ ស៊ីថា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣-ឯកឧត្តម **អ៊ុក ប្រាជ្ញា** | រដ្ឋលេខាធិការប្រចាំការក្រសួងព័ត៌មាន | សមាជិក |

| | | |
|---|---|---|
| ១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **ខៀវ ពិសេន** | អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩-ឯកឧត្តម **គង់ សោភ័ណ្ឌ** | អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល | សមាជិក |

ក្នុងករណីចាំបាច់ ប្រធាន **គ.ជ.ខ.** មានសិទ្ធិអញ្ជើញឥស្សរជនជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមប្រជុំ ឬផ្ដល់យោបល់តាមការចាំបាច់។

**គ.ជ.ខ.** អាចមានអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដែលត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន **គ.ជ.ខ.**។

**គ.ជ.ខ.** មានគណៈកម្មការប្រតិបត្តិមួយជាសេនាធិការទទួលបន្ទុកក្នុងការអនុវត្តវិធានការបិទខ្ទប់។

**ប្រការ៧ ..**

គណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ មានភារកិច្ច ដូចខាងក្រោម៖

- ដាក់ចេញនូវវិធានការលម្អិត ឬការណែនាំលម្អិតនានា សំដៅធានាដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលត្រូវបានបិទខ្ទប់ ក៏ដូចជាទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត
- ដាក់ចេញនូវគោលនយោបាយ និងវិធានការដើម្បីគាំពារ និងជួយសង្គ្រោះដល់ជនក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលបិទខ្ទប់
- ជួយគាំទ្រដល់គណៈកម្មការប្រតិបត្តិរបស់ **គ.ជ.ខ.** ក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធសំដៅធានាការអនុវត្តវិធានការបិទខ្ទប់ឱ្យបានរលូន និងមានប្រសិទ្ធភាព
- អនុវត្តនូវវិធានការចាំបាច់ផ្សេងទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល
- រាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាលអំពីលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តវិធានការបិទខ្ទប់។

**ប្រការ៨ ..**

ត្រូវបានប្រគល់ភារកិច្ចជូនគណៈអភិបាលរាជធានីភ្នំពេញ និងគណៈអភិបាលខេត្តកណ្ដាល ដើម្បីធ្វើជាគណៈកម្មការប្រតិបត្តិដែលជាសេនាធិការឱ្យ **គ.ជ.ខ.** ក្នុងការទទួលបន្ទុកអនុវត្តវិធានការបិទខ្ទប់ស្របតាមសេចក្ដីសម្រេចនេះ។ គណៈកម្មការប្រតិបត្តិនេះ ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញទទួលបន្ទុករួម និងមានអភិបាលនៃគណៈអភិបាលខេត្តកណ្ដាលជាអនុប្រធានទទួលបន្ទុកការងារបិទខ្ទប់សម្រាប់ភូមិសាស្ត្រក្រុងតាខ្មៅ។

គណៈកម្មការប្រតិបត្តិនៃ **គ.ម.ខ.** មានសិទ្ធិបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ ក្រសួង ស្ថាប័ននានា ត្រូវចាត់បញ្ជូនតំណាងរបស់ខ្លួនដើម្បីដឹកនាំ និង/ឬចូលរួមក្នុងក្រុមការងារតាមការស្នើសុំរបស់ប្រធានគណៈកម្មការប្រតិបត្តិនៃ **គ.ម.ខ.** ក្នុងក្របខណ្ឌនៃសមត្ថកិច្ចជំនាញ និងការទទួលខុសត្រូវរបស់ខ្លួន ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលត្រូវបានបិទខ្ទប់ ក៏ដូចជាទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

គណៈកម្មការប្រតិបត្តិនៃ **គ.ម.ខ.** មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៩** .-

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការរដ្ឋបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលសេចក្តីសម្រេចនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**ប្រការ១០** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់**
**ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល**
**ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- បានឃើញសេចក្ដីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្ដីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

### ប្រការ១ ..

វិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ដូចមានចែងក្នុងប្រការ២ និងប្រការ៣ នៃសេចក្ដីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្ដីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានកែសម្រួលដូចតទៅ៖

### ប្រការ២ .. ថ្មី

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នេះ បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន។ ក្នុងករណីមានការបំពានវិធានការហាមឃាត់ការធ្វើដំណើរនេះ អាជ្ញាធរអនុវត្តវិធានការបិទខ្ទប់ត្រូវអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ ដោយរួមទាំងការឃាត់ទុកជាបណ្ដោះអាសន្ននូវមធ្យោបាយធ្វើដំណើរ ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅប្រកបមុខរបរឬអាជីវកម្ម ឬបំពេញការងារក្នុងវិស័យឯកជន ដែលត្រូវបានអនុញ្ញាតដោយប្រការ៣ថ្មី នៃសេចក្ដីសម្រេចនេះ នៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដោយត្រូវមានលិខិតអនុញ្ញាតធ្វើដំណើរពីគណៈកម្មការប្រតិបត្តិនៃ **គ.ច.ខ.** អមដោយឯកសារសម្គាល់អត្តសញ្ញាណ និងលិខិតបញ្ជាក់ការងារដែលមានកំណត់ច្បាស់លាស់ពីឈ្មោះ មុខងារ និងប្រភេទអាជីវកម្មចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ។ គណៈកម្មការប្រតិបត្តិនៃ **គ.ច.ខ.** ត្រូវចេញសេចក្ដីណែនាំលម្អិតអំពីបែបបទនិងនីតិវិធីនៃការស្នើសុំ និងការផ្ដល់លិខិតអនុញ្ញាតធ្វើដំណើរនេះ។
- ការធ្វើដំណើរទៅបំពេញការងារក្នុងក្រសួងស្ថាប័ន នៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ និងដោយមានភ្ជាប់ឯកសារសម្គាល់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មរបស់ក្រសួងស្ថាប័នសាមី។
- ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ ឱសថស្ថាន និងទីកន្លែងលក់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដែលអនុញ្ញាតឱ្យបើកដំណើរការដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើដំណើរក្នុងគោលបំណងនេះ អាចធ្វើឡើងដោយសមាជិកយ៉ាងច្រើន ២ (ពីរ) នាក់ ក្នុងមួយ

លំនៅឋានឬទីសំណាក់ ដោយមិនឱ្យលើសពី ៣(បី) ដង ក្នុងមួយសប្តាហ៍ និងនៅទីតាំងដែលជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រក្រុង ឬខណ្ឌដែលខ្លួនរស់នៅ ដោយត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួន។

- ការធ្វើដំណើរទៅមន្ទីរពេទ្យ បណ្តុលសុខភាព សម្ភព ឬទីកន្លែងព្យាបាល ដោយមូលហេតុសុខភាពបន្ទាន់ នៅក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់នេះ ចេញក្រៅឬចូលក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់ ដោយកំណត់ចំនួនមនុស្សមិនឱ្យលើសពី ៤ (បួន) នាក់សម្រាប់ករណីនីមួយៗ ប៉ុន្តែត្រូវអនុវត្តដាច់ខាតនូវកាតព្វកិច្ចទាក់ទងនឹងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព។
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ នៅតាមទីតាំងតាមការកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។
- ការធ្វើដំណើរដើម្បីទៅទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី២ តាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។ ចំពោះការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ នៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ត្រូវបានផ្អាកជាបណ្តោះអាសន្ននៅក្នុងអំឡុងពេលបិទខ្ទប់។
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។
- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលនៅក្នុងលំនៅឋាន ឬទីសំណាក់របស់ខ្លួន ដោយមិនអនុញ្ញាតឱ្យធ្វើសកម្មភាពកីឡានេះនៅខាងក្រៅលំនៅឋាន ឬទីសំណាក់របស់ខ្លួនឡើយ។
- ការធ្វើដំណើររបស់ជនបរទេសដែលជាមន្ត្រីការទូត, មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស, ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដែលជាមន្ត្រីរបស់អង្គការហិរញ្ញវត្ថុអន្តរជាតិ ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ និងអាចអមដោយអ្នកបើកបររថយន្តជាជនជាតិខ្មែរ។
- ការធ្វើដំណើររបស់អ្នកសារព័ត៌មាន ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ ព្រមទាំងមានលិខិតអនុញ្ញាតសម្រាប់ការធ្វើដំណើរពីក្រសួងព័ត៌មាន។ ចំនួនបុគ្គលិករបស់អង្គភាពព័ត៌មាននីមួយៗ ត្រូវកាត់បន្ថយមកនៅត្រឹមកម្រិតអប្បបរមា សម្រាប់ទទួលការអនុញ្ញាតឱ្យធ្វើដំណើរដោយក្រសួងព័ត៌មាន។
- ការធ្វើដំណើរតាមផ្លូវអាកាស និងការធ្វើដំណើរទៅនិងមកពីអាកាសយានដ្ឋានក្នុងតំបន់បិទខ្ទប់ ដោយត្រូវគោរពតាមបទប្បញ្ញត្តិ និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាលជាធរមាន និងត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ ព្រមទាំងឯកសារពាក់ព័ន្ធនឹងការធ្វើដំណើរ និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។

រាល់ការលើកលែងខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៣_ថ្មី**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវបានហាមឃាត់រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។

ប៉ុន្តែ សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ ប៉ុន្តែ ប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ ដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។ ការធ្វើដំណើររបស់មន្ត្រីនៃស្ថាប័នសាធារណៈសម្រាប់គោលបំណងនេះ ត្រូវភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មដែលចេញដោយស្ថាប័នសាមី។ ប្រធានស្ថាប័នសាមី ត្រូវសម្រេចផ្អាកការងារដែលមិនចាំបាច់ជាបណ្ដោះអាសន្នក្នុងអំឡុងពេលបិទខ្ទប់ និងត្រូវណែនាំតាមការជាក់ស្ដែង ដើម្បីអាចឱ្យមន្ត្រីបំពេញការងារពីចម្ងាយ ឬតាមរយៈប្រព័ន្ធអនឡាញ។
- សកម្មភាពការងាររបស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមន្ត្រីនិងបុគ្គលិកសុខាភិបាល ត្រូវដំណើរការស្របតាមការចាំបាច់ និងតាមការកំណត់របស់ប្រធានស្ថាប័ននីមួយៗ។
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតឱសថ និងសម្ភារៈបរិក្ខាពេទ្យ រួមទាំងម៉ាសអាកុល និងអុកស៊ីសែន។
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីសត្តឃាត ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។
- សកម្មភាពការងារដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ តាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាពន្លត់អគ្គិភ័យ, សេវាផ្គត់ផ្គង់អគ្គិសនី, សេវាទឹកស្អាត, សេវាកំពង់ផែ, សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង ជាដើម។ ចំពោះសេវាផ្គត់ផ្គង់អគ្គិសនី, សេវាទឹកស្អាត និងសេវាកំពង់ផែ ប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការនៅការិយាល័យឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែបុគ្គលិកឬមន្ត្រីទទួលបន្ទុកខាងផ្នែកប្រតិបត្តិការ និងសង្វាក់ផលិតកម្ម ដែលត្រូវបំពេញការងារជាប្រក្រតីធម្មតា។ ការធ្វើដំណើររបស់មន្ត្រី ឬបុគ្គលិកដើម្បីបម្រើឱ្យសេវាទាំងនេះ ត្រូវភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មដែលចេញដោយស្ថាប័នសាមី។

- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ ដោយត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ។
- ការផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ផ្សារលក់ដុំ ផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្តាប់ធ្នាប់ ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់, ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស, ទីតាំងលក់ហ្គាស, ឬទីតាំងផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះផ្សារ ឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគ ភោជនីយដ្ឋាន-អាហារដ្ឋាន អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់ត្រូវធ្វើការត្រួតពិនិត្យ និងសម្រេចអនុញ្ញាត ទៅតាមការជាក់ស្តែងដោយផ្អែកទៅលើតម្រូវការចាំបាច់នៅក្នុងភូមិសាស្ត្ររបស់ខ្លួន។
- ការផ្គត់ផ្គង់សេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋ និងឯកជន, ឱសថស្ថាន, សេវាប្រៃសណីយ៍-ទូរគមនាគមន៍, សេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន ដែលត្រូវដំណើរការជាប្រក្រតីធម្មតា។
- សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់ ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារ និងការស្នាក់នៅនៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែសណ្ឋាគារដែលបម្រើឱ្យការធ្វើចត្តាឡីស័ក ដែលចំនួនបុគ្គលិកអប្បបរមា និងពេលម៉ោងធ្វើការរបស់បុគ្គលិក ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។
- សេវាកម្មដឹកជញ្ជូនម្ហូបអាហារឬគ្រឿងឧបភោគបរិភោគ ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ សកម្មភាពនៃការដឹកជញ្ជូននេះ មិនត្រូវបានអនុញ្ញាតឱ្យមានការដឹកជញ្ជូនមនុស្សឡើយ។
- សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ចនៃប្រទេស។ សកម្មភាពនៃការដឹកជញ្ជូននេះ មិនត្រូវបានអនុញ្ញាតឱ្យមានការដឹកជញ្ជូនមនុស្សឡើយ។
- ចំពោះការគ្រប់គ្រង និងថែរក្សាឃ្លាំងស្តុកទំនិញ ឬគ្រឿងឧបភោគបរិភោគ ត្រូវបានអនុញ្ញាតឱ្យមានបុគ្គលិកប្រចាំការក្នុងចំនួនអប្បបរមា និងត្រូវអនុវត្តគោលការណ៍អាហារ និងការស្នាក់នៅនៅហ្នឹងកន្លែងបំពេញការងារ។
- ការដឹកជញ្ជូនបុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល ដោយមានការអនុញ្ញាត និងការសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ច និង

- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ២ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ៦កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបន្តហាមឃាត់ការធ្វើដំណើរ និងបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេស ជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្តីសម្រេចលេខ ៤៤ សសរ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១ .-**

បន្តអនុវត្តការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលត្រូវបានសម្រេចដោយសេចក្តីសម្រេចលេខ ៤៤ សសរ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃបន្តទៀត រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១។

បទប្បញ្ញត្តិផ្សេងទៀតនៃសេចក្តីសម្រេចលេខ ៤៤ សសរ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ ស្តីពីការហាមឃាត់ការធ្វើដំណើរ និងការបិទរមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ៦កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ៩១២ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារអន្តរក្រសួង
# ដើម្បីចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃលើការស្នើសុំបង្កើតភូមិថ្មី

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃលើការស្នើសុំបង្កើតភូមិថ្មី ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ឯកឧត្តម **លេខ ទី** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម **ធ្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៤. | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. | តំណាងក្រសួងមុខងារសាធារណៈ | សមាជិក |
| ៦. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧. | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៨. | ឯកឧត្តម **សួស ធ្រាវ៉ា** អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៩. | នាយករដ្ឋបាលរាជធានី ខេត្ត | សមាជិក។ |

**ប្រការ ២.-**

ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ចុះសិក្សា និងស្រាវជ្រាវលើសំណើសុំបង្កើតភូមិថ្មីរបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលសម្រេចបាន និងវឌ្ឍនភាពការងារជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេច និងផ្តល់យោបល់ដឹកនាំ
- ពិនិត្យ វាយតម្លៃ និងលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ ៣.-**

ប្រធានក្រុមការងារអន្តរក្រសួងមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមកិច្ចប្រជុំពិភាក្សាតាមការចាំបាច់។

អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួងត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារអន្តរក្រសួង។

ក្រុមការងារអន្តរក្រសួងមានសិទ្ធិចាត់ចែងមន្ត្រីក្រោមឱវាទដើម្បីជួយបំពេញការងារតាមការចាំបាច់។

ក្រុមការងារអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

**ប្រការ ៤.-**

ថវិកាចំណាយ មធ្យោបាយ និងសម្ភារបរិក្ខារសម្រាប់បំពេញបេសកកម្មការងាររបស់ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារអន្តរក្រសួង ជាបន្ទុករបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលរាជធានី ខេត្ត និងសាមីខ្លួន ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥១៣ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្ត
# គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស០១៧/០៥០៨/រកម/ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ៨៧៤ សហវ.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩ - ២០២៥ ដែលបានទទួលការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្ដីពី *ការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត* ដូចមានខ្លឹមសារភ្ជាប់មកជាមួយប្រកាសនេះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាព និងកែតម្រូវគោលការណ៍ណែនាំនេះ តាមការចាំបាច់ដើម្បីធានាប្រសិទ្ធភាពនៃការដាក់ឱ្យអនុវត្តថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត។

**ប្រការ ២ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំថវិកាកម្មវិធីដោយផ្អែកលើគោលការណ៍ណែនាំនេះ។

**ប្រការ ៣ .-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កន្លែងទទួល÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# គោលការណ៍ណែនាំ
# ស្តីពី
# ការរៀបចំថវិកាកម្មវិធី
# សម្រាប់រដ្ឋបាលរាជធានី ខេត្ត

ឆ្នាំ ២០២០

# មាតិកា

**សន្ទានុក្រម**

**ផ្នែកទី ១- សេចក្តីផ្តើម**........................................................................................ ១

**ផ្នែកទី ២ - អត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធី**......................................................៣

**ផ្នែកទី ៣- ដំណើរការនៃការរៀបចំថវិកាកម្មវិធី**.............................................................៥

**ជំហានទី១-** ការផ្តើមចេញពីផែនការយុទ្ធសាស្ត្រថវិកា......................................................៥

**ជំហានទី២-** វិធីសាស្ត្របង្កើតរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព.....៥

**ជំហានទី៣-** វិធីសាស្ត្រកំណត់គោលបំណងនៃរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព ..៧

**ជំហានទី៤-** វិធីសាស្ត្រក្នុងការកំណត់ខ្សែសង្វាក់លទ្ធផល...............................................១២

**ជំហានទី៥-** ពិនិត្យឡើងវិញលើឡូជីកនៃការកសាងរចនាសម្ព័ន្ធកម្មវិធី...............................១៩

**ជំហានទី៦-** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ...........................................................២០

**ជំហានទី៧-** វិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី..............................២៧

**ជំហានទី៨-** ការត្រួតពិនិត្យឡើងវិញលើថវិកាកម្មវិធីដែលបានកសាង...............................៣៣

**ផ្នែកទី ៤- ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកា** ...............................................៣៧

**ផ្នែកទី៥-ឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២**

# សន្ទានុក្រម

| ល.រ | ពាក្យគន្លឹះ | Key Words | អត្ថន័យ |
|---|---|---|---|
| ១ | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩- ២០២៥ | Subnational Administration-Budget System Reform Strategy (SNA-BSRS) | សំដៅដល់ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិរយៈពេលវែង និងគ្រប់ជ្រុងជ្រោយ ដោយបានកំណត់អំពីទិសដៅនិងក្របខ័ណ្ឌពេលវេលាច្បាស់លាស់និងបានដាក់ចេញផែនការសកម្មភាពកែទម្រង់តាមអភិក្រមសាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព ស្របតាមសមត្ថភាព និងតថភាពជាក់ស្តែងនៃកម្ពុជា។ |
| ២ | ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត | Capital and Province/ Budget Strategic Plan (CP/BSP) | សំដៅលើផែនការយុទ្ធសាស្ត្ររយៈពេលពាឆ្នាំរំកិលត្រូវបានរៀបចំប្រចាំឆ្នាំ ដោយមានលក្ខណៈសមាហរណកម្មដែលជាឧបករណ៍ផ្សារភ្ជាប់ទំនាក់ទំនងគោលនយោបាយជាតិជាមួយនឹងផែនការយុទ្ធសាស្ត្រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើឱ្យផែនការថវិកាមានការផ្សារភ្ជាប់ជាមួយនឹងគោលបំណងគោលនយោបាយតែមួយ។ |
| ៣ | ផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | Five-Year Development Plan of Subnational Administration | សំដៅដល់ផែនការអភិវឌ្ឍន៍ ដែលត្រូវបានរៀបចំ៥ឆ្នាំម្តងដោយរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ វាជាការរៀបចំផែនការតាមវិស័យ ដែលផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ចំពោះអាទិភាពតាមវិស័យនៅមូលដ្ឋាន និងធ្វើជាមគ្គុទេសក៍សម្រាប់កម្រិតអនុវត្ត និងតម្រែតម្រង់ការផ្តល់សេវារបស់ខ្លួនឱ្យឆ្លើយតបទៅនឹងអាទិភាពជាតិ។ |
| ៤ | កម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | Three-Year Rolling Investment Program of Subnational Administration | សំដៅដល់ការរៀបចំកម្មវិធីវិនិយោគរយៈពេលមធ្យម (៣ឆ្នាំ) នៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ វាជាការរៀបចំផែនការវិនិយោគតាមវិស័យ ដែលផ្តោតការយកចិត្តទុកដាក់ច្បាស់លាស់ចំពោះអាទិភាពតាមវិស័យនៅមូលដ្ឋាន និងត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ |

| | | | |
|---|---|---|---|
| ៥ | ក្របខ័ណ្ឌថវិការយៈពេលមធ្យម | Medium-Term Budget Framework (MTBF) | សំដៅលើការរៀបចំក្របខ័ណ្ឌចំណូល ចំណាយថវិការយៈពេលមធ្យម(បីឆ្នាំ) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ៦ | ថវិកាផ្តោតលើធាតុចូល | Input Base Budgeting | សំដៅដល់ការរៀបចំថវិកាផ្តោតទៅលើតម្រូវការធាតុចូលទៅតាមជំពូក គណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។ |
| ៧ | ថវិកាកម្មវិធី | Program Budgeting | សំដៅដល់ការរៀបចំថវិកាផ្អែកលើកម្មវិធីច្បាស់លាស់ និងប្រើប្រាស់កម្មវិធីជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ។ |
| ៨ | ការធ្វើសមាហរណកម្មផែនការនីយកម្ម | Integration of Planning | សំដៅដល់ការធ្វើសុខដុមនីយកម្មកិច្ចដំណើរការធ្វើផែនការ ដែលក្នុងនោះរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវធ្វើឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នានិងប្រទាក់ក្រឡាគ្នាទៅវិញទៅមក ដោយការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នសម្រាប់ថវិកាមន្ទីរជំនាញ រាជធានី ខេត្ត។ |
| ៩ | ការធ្វើសមាហរណកម្មផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | Integration of Program Activities at Subnational Levels | សំដៅដល់ការគ្រោងផែនការសកម្មភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ មានលក្ខណៈប្រមូលផ្តុំ ដោយតម្រង់ទិស បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ ដើម្បីគាំទ្រដល់អាទិភាពគោលនយោបាយនៅមូលដ្ឋាន ដែលជាវិភាគទានទៅដល់ការសម្រេចបានអាទិភាពតាមវិស័យ និងអាទិភាពជាតិ។ |
| ១០ | ការតម្រឹម | Alignment | សំដៅលើការតម្រឹមផែនការ/កម្មវិធីនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័ន ដើម្បីប្រើប្រាស់ធនធានដែលមានកម្រិតដើម្បីសម្រេចបានសមិទ្ធផលជាអតិបរមា។ ក្នុងន័យនេះ នៅពេលរៀបចំផែនការ/កម្មវិធីរបស់ខ្លួន រដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យមើលផែនការឬវិស័យអាទិភាពដែលមន្ទីរជំនាញបានគ្រោង ។ប្រសិនបើជាពិនិត្យឃើញថា ផែនការ |

| | | | |
|---|---|---|---|
| | | | ឬវិស័យអាទិភាពនោះមានភាពចាំបាច់ ហើយមន្ទីរជំនាញរាជធានី ខេត្តមិនបានគ្រោង នោះរដ្ឋបាលរាជធានី ខេត្តអាចរៀបចំផែនការអន្តរាគមន៍របស់ខ្លួនដើម្បីអនុវត្តសកម្មភាពនោះ។ |
| ១១ | បច្ច័យ | Impacts | សំដៅលើឥទ្ធិពលជាវិជ្ជមានស្របតាមម៉ូឌែលឡូជីកដែលជាការកំណត់លទ្ធផលចុងក្រោយពិតប្រាកដសម្រាប់កម្មវិធី (ឧ.ការថយចុះភាពក្រីក្រ,អត្រាអ្នកមានការងារធ្វើកើនឡើង...)។ ការធ្វើការវាយតម្លៃលើបច្ច័យ គឺមានរយៈពេល ៥ ឆ្នាំម្តង។ |
| ១២ | លទ្ធផលចុងក្រោយ | Outcomes | សំដៅដល់លទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំក្រោយពីការអនុវត្តបានពេញលេញនូវកម្មវិធីក្នុងរយៈពេលកំណត់មួយ។ |
| ១៣ | លទ្ធផលក្នុងឆ្នាំ | Outputs | សំដៅលើលទ្ធផលសម្រេចបាននូវសូចនាករ និងគោលដៅប្រចាំឆ្នាំនៃការអនុវត្តចង្កោមសកម្មភាព និងអនុវត្តកម្មវិធីស្របតាមការទទួលខុសត្រូវនៃរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធីប្រចាំឆ្នាំ។ |
| ១៤ | ឡូជីកនៃកម្មវិធី | Program Logic | សំដៅលើការរៀបចំផែនការយុទ្ធសាស្ត្រដោយផ្សារភ្ជាប់នឹងសមិទ្ធកម្មទៅតាមឋានុក្រម (ឧ. សូចនាករសម្រាប់កម្រិតគោលបំណងគោលនយោបាយ និងកម្រិតកម្មវិធីគឺជា លទ្ធផលចុងក្រោយ រីឯកម្រិតអនុកម្មវិធីចុះក្រោមគឺលទ្ធផលក្នុងឆ្នាំ)។ |
| ១៥ | ក្របខ័ណ្ឌវាយតម្លៃ | Evaluation Framework | សំដៅដល់ការរៀបចំក្របខ័ណ្ឌអភិក្រមគ្រប់ជ្រុងជ្រោយមួយដើម្បីសម្រេចជំហានបន្ទាប់បាន លុះត្រាតែសម្រេចបានសមាសភាពជាមូលដ្ឋាន (ឧ. ដើម្បីអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មបាន លុះត្រាតែមានសមាសធាតុសំខាន់ត្រូវបានរៀបចំ រួមមាន ថវិកាកាន់តែទុកចិត្តបាន, មានប្រព័ន្ធFMIS, គុណភាពផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធី)។ |

| | | | |
|---|---|---|---|
| ១៦ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | Key Performance Indicator Target (KPI Target) | សំដៅដល់កម្រិតនៃការរំពឹងទុកនៃសមិទ្ធកម្ម ដែលត្រូវបានកំណត់ជាលេខ, ភាគរយ, ពេលវេលា និងកន្លែងណាមួយដែលអាចជឿទុកចិត្តបានថានឹងសម្រេចបានក្នុងពេលវេលាជាក់លាក់ណាមួយ។ |
| ១៧ | សូចនាករសមិទ្ធកម្មគន្លឹះ | Key Performance Indicator (KPI) | សំដៅដល់ឧបករណ៍សម្រាប់ធ្វើការវាស់វែងវឌ្ឍនភាពនៃការអនុវត្តសកម្មភាព, លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។ សូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាគឺជាចំណុចវិជ្ជមានក្នុងការជំរុញឱ្យផ្តោតការយកចិត្តទុកដាក់លើសមិទ្ធកម្មឱ្យបានកាន់តែខ្លាំងឡើង ជាពិសេស បានធ្វើឱ្យដំណើរការរៀបចំ និងអនុវត្តថវិកាកម្មវិធីកាន់តែមានប្រសិទ្ធភាព និងគ្រប់គ្រងបាន។ |
| ១៨ | វិធីសាស្ត្រ SMART | SMART (Specific, Measurable Attainable Relevant Timeframe) | សំដៅដល់វិធីសាស្ត្រដើម្បីធានាថាលទ្ធផលចុងក្រោយ និងលទ្ធកម្មក្នុងឆ្នាំត្រូវបានរៀបចំ និងវាស់វែងដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ដែលមានលក្ខណៈ SMART (ជាក់លាក់, អាចវាស់វែង, អាចសម្រេចបាន, ពាក់ព័ន្ធ និងមានពេលកំណត់) ដើម្បីឆ្លើយតបទៅនឹងគោលដៅសមិទ្ធកម្មសមស្រប។ |
| ១៩ | មន្ត្រីបច្ចេកទេសថវិកា | Budget Technical Official | សំដៅដល់មន្ត្រីជំនាញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជួយការគាំទ្រ និងសម្របសម្រួលផ្នែកបច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម។ |
| ២០ | ក្រុមការងារថវិកា | Budget Working Group | សំដៅដល់ក្រុមការងាររបស់រដ្ឋបាលរាជធានី ខេត្ត ដែលទទួលការងារសម្របសម្រួលជាមួយនឹងគ្រប់ទីចាត់ការនៃរដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធី និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្ម។ |

*បញ្ជាក់÷ សន្ទានុក្រមនេះ គឺជាការប្រមូលផ្តុំ និងការពន្យល់ពាក្យបច្ចេកទេសខ្លះៗ ដែលបានប្រើប្រាស់ក្នុងគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីនេះ តែប៉ុណ្ណោះ។*

# ផ្នែកទី ១
# សេចក្តីផ្តើម

**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥** បានឆ្លុះបញ្ចាំងនូវគោលបំណងនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាគន្លឹះៗ ដើម្បីធានារាល់ការចំណាយសាធារណៈទាំងអស់ គឺឈានឆ្ពោះទៅរកការសម្រេចបានគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅរកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និងវិមជ្ឈការកាន់តែប្រសើរឡើង។ ការអនុវត្តផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត និងថវិកាកម្មវិធី នឹងជួយពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងថវិកាទៅនឹងគោលនយោបាយកាន់តែមានប្រសិទ្ធភាព និងបានបង្កើតជាមូលដ្ឋានកាន់តែរឹងមាំសម្រាប់ឈានទៅអនុវត្តប្រព័ន្ធថវិកាផ្តោតលើគណនេយ្យភាពសមិទ្ធកម្ម ដែលជាទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដំណាក់កាលទី ៤។

*«គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត»* ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានគោលដៅពង្រឹងការផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតរវាងគោលនយោបាយជាមួយនឹងការរៀបចំថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងអាទិភាពតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត) ជាមួយនឹងផែនការ/កម្មវិធីនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដំណើរការនៃការផ្សារភ្ជាប់គ្នារវាងផែនការ/កម្មវិធីនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងអាទិភាពជាតិតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិកាន់តែមានប្រសិទ្ធភាពនឹងធ្វើឱ្យការប្រើប្រាស់ធនធាន ដែលមានកម្រិតដើម្បីសម្រេចបានសមិទ្ធផលជាអតិបរមា។ តាមទិសដៅនេះ រចនាសម្ព័ន្ធកម្មវិធីនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានកែសម្រួលឡើងវិញ ដើម្បីឱ្យមានសង្គតិភាពជាមួយវិស័យអាទិភាពថ្នាក់ជាតិ។ សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវបានរៀបចំឱ្យមានមានលក្ខណៈ SMART (ជាក់លាក់, អាចវាស់វែង, អាចសម្រេចបាន, ពាក់ព័ន្ធ និងមានពេលកំណត់) ដែលអាចឆ្លើយតបទៅនឹងគោលដៅនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។

ដើម្បីសម្រេចបានទិសដៅខាងលើនេះ ចាំបាច់ត្រូវមានការសម្របសម្រួល និងពិគ្រោះយោបល់ក្នុងចំណោមគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ *«គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស»* ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានសមាសភាពពីមន្ទីរជំនាញរាជធានី ខេត្ត និងភាគីពាក់ព័ន្ធ

ទាំងអស់ នឹងត្រូវដើរតួនាទីសំខាន់ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។ ជាមួយគ្នានេះ ការបង្កើតឱ្យមានយន្តការគាំទ្រពីថ្នាក់ជាតិ ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺមានភាពចាំបាច់ណាស់។ តាមរយៈនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំក្រុមការងារបច្ចេកទេសកម្រិតថ្នាក់ជាតិមួយ ហៅថា *«មន្ត្រីបច្ចេកទេសថវិកា»* ដើម្បីជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត។ ដោយឡែក រដ្ឋបាលរាជធានី ខេត្ត ក៏ត្រូវត្រៀមរៀបចំ *«ក្រុមការងារថវិកា»* ដើម្បីផ្តល់ការសហការលើកិច្ចការនេះផងដែរ។

*«គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលរាជធានី ខេត្ត»* ជាមគ្គុទ្ទេសក៍សម្រាប់ជួយណែនាំអំពីវិធីសាស្ត្រនៃការរៀបចំថវិកាកម្មវិធីដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត ដើម្បីធានាថាកម្មវិធី ដែលបានកសាងឈានទៅសម្រេចបានគោលបំណងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងនេះក្តី គោលការណ៍ណែនាំនេះ ជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដើម្បីកែលម្អ និងធានាឱ្យការអនុវត្តថវិកាកម្មវិធីមានភាពស័ក្តិសិទ្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តធ្វើការកែលម្អគោលការណ៍ណែនាំនេះពីមួយឆ្នាំទៅមួយឆ្នាំទៅតាមបទពិសោធន៍នៃការអនុវត្តជាក់ស្តែងដើម្បីឱ្យគោលការណ៍ណែនាំនេះកាន់តែមានសុក្រឹត្យភាព ពិសេសធានាបាននូវការអនុវត្តថវិកាកម្មវិធីមួយដែលសមស្របសម្រាប់កម្ពុជា។

គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី ចែកចេញជា៥ផ្នែក រួមមាន÷ **ផ្នែកទី១**-សេចក្តីផ្តើម **ផ្នែកទី២**-អត្ថប្រយោជន៍នៃកាអនុវត្តថវិកាកម្មវិធី **ផ្នែកទី៣**-ដំណើរការនៃការរៀបចំថវិកាកម្មវិធី **ផ្នែកទី៤**-ការពិនិត្យតាមដានវាយតម្លៃ ការអនុវត្ត និងការធ្វើរបាយការណ៍ និង **ផ្នែកទី៥**-ឧបសម្ព័ន្ធ។

# ផ្នែកទី ២

# អត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធី

**ថវិកាកម្មវិធី** គឺជាការរៀបចំថវិកាប្រចាំឆ្នាំដោយផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចបានផែនការ/កម្មវិធីនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាទិភាពជាតិតាមវិស័យនៃក្រសួង ស្ថាប័នថ្នាក់ជាតិ។ ការរៀបចំថវិកាកម្មវិធី គឺជាដំណាក់កាលទី២ បន្ទាប់ពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។

ថវិកាកម្មវិធី ត្រូវមានសូចនាករសមិទ្ធកម្មគន្លឹះ (KPI) សម្រាប់វាស់វែង និងធ្វើរបាយការណ៍លទ្ធផលចុងក្រោយ (Outcome) នៃកម្មវិធី និងលទ្ធផលក្នុងឆ្នាំ (Output) នៃអនុកម្មវិធី និងចង្កោមសកម្មភាព។ ថវិកាកម្មវិធីត្រូវកំណត់ឱ្យបានច្បាស់នូវធាតុចូល ដែលរួមមាន ចំណាយចរន្ត និងចំណាយមូលធនដែលចាំបាច់សម្រាប់ការអនុវត្តកម្មវិធី, អនុកម្មវិធី និងចង្កោមសកម្មភាព។

ថវិកាកម្មវិធី នឹងផ្ដល់ជាមធ្យោបាយដើម្បីធ្វើការពិនិត្យឡើងវិញអំពីការវិភាជន៍ធនធានដែលបានរៀបចំនៅក្នុងដំណាក់កាលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជាពិសេសផ្ដល់លទ្ធភាពពិនិត្យ និងថ្លឹងថ្លែងឡើងវិញរវាងអាទិភាពគោលនយោបាយចាស់ និងគោលនយោបាយថ្មីនៅពេលរៀបចំថវិកាឆ្នាំបន្ទាប់។

ផ្ទុយទៅវិញ, ការរៀបចំថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា គឺជាការរៀបចំថវិកាដោយផ្ដោតតែលើមូលដ្ឋានតម្រូវការធាតុចូលទៅតាមប្រភេទ ជំពូក គណនី និងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។ ការរៀបចំថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាមិនអាចឱ្យយើងសម្រេចបានគោលបំណងគោលនយោបាយ ឬវិស័យអាទិភាពបានទាំងស្រុងទេ ពីព្រោះការរៀបចំថវិកាតាមបន្ទាត់មាតិកាថវិកាអនុញ្ញាតឱ្យយើងកត់ត្រាបានតែមុខសញ្ញាចំណាយតាមបែបសេដ្ឋកិច្ច ដែលបម្រើតែគោលដៅរបាយ-ការណ៍ហិរញ្ញវត្ថុប៉ុណ្ណោះ។ ថវិកាតាមបន្ទាត់មាតិកាថវិកានេះ មិនបានជួយផ្សារភ្ជាប់ទំហំចំណាយលើធាតុចូលដែលបានផ្ដល់ទៅនឹងលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយដែលរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរំពឹងទុកនោះទេ។ ជាលទ្ធផល, ការអនុវត្តថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា បានបង្កើតជាផ្នត់គំនិតឱ្យរដ្ឋបាលរាជធានី ខេត្ត ទាមទារកំណើនថវិកាប្រចាំឆ្នាំដោយផ្អែកតែទៅលើថវិកាឆ្នាំកន្លងមក ដោយមិនបានយកចិត្តទុកដាក់ដល់សមិទ្ធកម្មឡើយ។

ជារួម, ការអនុវត្តថវិកាកម្មវិធី នឹងបង្កើតបានជាមូលដ្ឋានគ្រឹះ សម្រាប់កែលម្អនូវកត្តាមួយចំនួនដូចខាងក្រោម÷

- ✓ ការរៀបចំផែនការថវិកាប្រចាំឆ្នាំ តាមរយៈការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ឬអាទិភាពតាមវិស័យ,
- ✓ លទ្ធផលចុងក្រោយ (Outcome) និងលទ្ធផលក្នុងឆ្នាំ (Output) ដែលរដ្ឋបាលរាជធានី ខេត្ត សម្រេចបានតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ ឆ្លើយតបទៅនឹងថវិកាដែលបានចំណាយ,
- ✓ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ត្រូវបានពង្រឹង ស្របតាមអាទិភាពនៃគោលនយោបាយរបស់រដ្ឋាភិបាល,
- ✓ ការអនុវត្តថវិកា ដើម្បីជួយពង្រឹង និងបង្កើតឱ្យមានបន្ទាត់គណនេយ្យភាព ដែលជាមូលដ្ឋានកាន់តែរឹងមាំសម្រាប់ឈានទៅអនុវត្តប្រព័ន្ធថវិកាផ្តោតលើគណនេយ្យភាពសមិទ្ធកម្ម, និង
- ✓ ការតាមដាន វាយតម្លៃ និងការធ្វើរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកា។

# ផ្នែកទី ៣
# ដំណើរការនៃការរៀបចំថវិកាកម្មវិធី

រដ្ឋបាលរាជធានី ខេត្ត ដោយមាន «**ក្រុមការងារថវិកា**» ជាអ្នកជួយសម្របសម្រួល ត្រូវរៀបចំថវិកាកម្មវិធីប្រចាំឆ្នាំរបស់ខ្លួនទៅតាមជំហានទីមួយៗ ដូចខាងក្រោម÷

## ៣.១ ជំហានទី១- ការផ្តើមចេញពីផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត

ដើម្បីអាចរៀបចំថវិកាកម្មវិធីបានល្អ ចាំបាច់ត្រូវយល់ឱ្យបានច្បាស់នូវគោលដៅរបស់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពនីមួយៗ។ *ផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត* គឺជាផែនការរយៈពេលបីឆ្នាំរំកិល តាមអភិក្រមពីក្រោមឡើងលើ ដែលត្រូវបានរៀបចំប្រចាំឆ្នាំ ដោយផ្សារភ្ជាប់អាទិភាពគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងគោលដៅតាមវិស័យ និងផែនការអភិវឌ្ឍន៍ ជាពិសេស កម្មវិធីវិនិយោគពាធ្នាំរំកិល។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត គឺជាដំណាក់កាលទី១នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ត្រូវចាប់ផ្តើមចន្លោះខែមេសា និងឧសភា។ នៅក្នុងដំណាក់កាលទី២នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ គឺការរៀបចំកញ្ចប់ថវិកាដែលត្រូវចាប់ផ្តើមពីខែ មិថុនា ដល់ខែ កញ្ញា។ នៅក្នុងដំណាក់កាលទី២នេះ *«ក្រុមការងារថវិកា»* ដែលត្រូវបានបង្កើតឡើងដោយរដ្ឋបាលរាជធានី ខេត្ត ត្រូវពិនិត្យមើលឡើងវិញរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងផែនការអន្តរាគមន៍របស់រដ្ឋបាលរាជធានី ខេត្តសាមី ដែលបានគ្រោងនៅក្នុងឆ្នាំទី១ (ឆ្នាំ n+1)នៃផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ដែលត្រូវបានពិនិត្យ និងសម្រេចដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដែលនឹងត្រូវរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ជាក្របខ័ណ្ឌសម្រាប់ការរៀបចំផែនការថវិកាកម្មវិធីប្រចាំឆ្នាំ។

## ៣.២ ជំហានទី២- វិធីសាស្ត្របង្កើតរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព

*(ជំហានទី២ នេះ ផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងជួរឈរទី១ នៃតារាងឧបសម្ព័ន្ធទី ១.១, ១.២ និង ១.៣ ដូចមានជូនភ្ជាប់មកជាមួយ)*

### ៣.២.១ ការកំណត់អ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវ

ដើម្បីឱ្យការអនុវត្តថវិកាកម្មវិធីអាចប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព រដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ឱ្យមានអ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវចំពោះកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាពនីមួយៗ។ តារាងទី ១ ខាងក្រោម ផ្តល់នូវគោលការណ៍ និងអនុសាសន៍មួយចំនួន សម្រាប់កំណត់អ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវលើការអនុវត្តកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព។

*តារាងទី១÷ គោលការណ៍ និងអនុសាសន៍នៃការកំណត់អ្នកទទួលខុសត្រូវ/អង្គភាពទទួលខុសត្រូវ*

| | **គោលការណ៍** | **អនុសាសន៍** |
|---|---|---|
| **កម្មវិធី** | ✓ កម្មវិធីមួយត្រូវមានគោលបំណងច្បាស់លាស់មួយ<br>✓ កម្មវិធីមួយត្រូវមានសូចនាករលទ្ធផលចុងក្រោយ (Outcome) យ៉ាងហោចណាស់មួយ<br>✓ រដ្ឋបាលរាជធានី ខេត្តគួរមានកម្មវិធីច្រើនបំផុតបួន | កម្មវិធីគួរទទួលខុសត្រូវដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ |
| **អនុកម្មវិធី** | ✓ ចំនួនអនុកម្មវិធី គួរសមស្របទៅនឹងតម្រូវការជាក់ស្តែងរបស់កម្មវិធី ជាពិសេស ដើម្បីឆ្លើយតបទៅនឹងគោលបំណងរបស់កម្មវិធី<br>✓ អនុកម្មវិធីមួយ គួរមានសូចនាករលទ្ធផលក្នុងឆ្នាំមួយ ឬច្រើន ដើម្បីរួមវិភាគទានសម្រេចបានគោលបំណងរួម និងលទ្ធផលចុងក្រោយនៃកម្មវិធីមួយ | អនុកម្មវិធី គួរទទួលខុសត្រូវដោយអភិបាលរង/នាយករដ្ឋបាលស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ |
| **ចង្កោមសកម្មភាព** | ✓ ចង្កោមសកម្មភាព អាចមានចំនួនច្រើនដើម្បីសម្រេចបានអនុកម្មវិធីមួយ<br>✓ ចង្កោមសកម្មភាពមួយត្រូវមានសូចនាករលទ្ធផលក្នុងឆ្នាំយ៉ាងតិចមួយសម្រាប់វាស់វែងការអនុវត្តប្រចាំឆ្នាំ | ចង្កោមសកម្មភាពគួរទទួលខុសត្រូវដោយនាយករងរដ្ឋបាល/ នាយកទីចាត់ការ ស្របតាមរចនាសម្ព័ន្ធជាក់ស្តែងរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ |
| **សកម្មភាព** | ✓ សកម្មភាពអាចមានចំនួនច្រើនដើម្បីសម្រេច | គួរទទួលបន្ទុកដោយនាយករង |

| | | |
|---|---|---|
| | បានចង្កោមសកម្មភាពមួយ<br>✓ សកម្មភាពមួយត្រូវមានសូចនាករយ៉ាងតិចមួយសម្រាប់វាស់វែង។ | ទីចាត់ការ/ប្រធានការិយាល័យតាមវិស័យ |

*សម្គាល់÷សូមមើលបន្ថែមនៅក្នុងគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត*

**៣.២.២ ការបង្កើតកម្មវិធី**

ដូចក្នុងតារាងទី២ខាងក្រោម គ្រប់រដ្ឋបាលរាជធានី ខេត្តទាំងអស់ត្រូវមានគោលបំណងគោលនយោបាយចំនួន ១ និងមានកម្មវិធីចំនួន ៤។

*តារាងទី២÷ ទំនាក់ទំនងរវាងគោលបំណងគោលនយោបាយ និងកម្មវិធី*

| គោលបំណងគោលនយោបាយ | កម្មវិធី |
|---|---|
| **ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍរដ្ឋបាលសាធារណៈ និងសេវាសាធារណៈរាជធានី ខេត្ត** | ១. អភិវឌ្ឍវិស័យសេដ្ឋកិច្ច |
| | ២. ពង្រឹងវិស័យសង្គមកិច្ច |
| | ៣. លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ |
| | ៤. ពង្រឹងរដ្ឋបាលទូទៅ |

គ្រប់កម្មវិធីទាំងអស់ ដែលបានរៀបចំ ចាំបាច់ត្រូវមានគោលដៅច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការរៀបចំរចនាសម្ព័ន្ធអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព និងធ្វើការតាមដាន និងវាស់វែងលើការសម្រេចបានលទ្ធផលចុងក្រោយ (Outcomes) នៃកម្មវិធីនីមួយៗ។

- ✓ **កម្មវិធីទី១-អភិវឌ្ឍវិស័យសេដ្ឋកិច្ច÷** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈក្នុងវិស័យសេដ្ឋកិច្ច ដែលជាកម្មវិធីដើម្បីកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដូចជា÷ ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងចំណូល និងចំណាយ។ **ឧទាហរណ៍÷** ការកសាង និងការជួសជុលផ្លូវ, ប្រព័ន្ធលូ, ប្រឡាយទឹក និងផ្សេងៗ លើកលែងការកសាង និងការជួសជុលអាគាររដ្ឋបាល និងសួនច្បារសាធារណៈ។
- ✓ **កម្មវិធីទី២-ពង្រឹងវិស័យសង្គមកិច្ច÷** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈក្នុងវិស័យសង្គមកិច្ច ដូចជា÷ ការលើកកម្ពស់វិស័យសង្គមកិច្ច (ដូចជា កីឡា, វប្បធម៌, អប់រំ, សុខាភិបាល និង

បរិស្ថាន) ការបង្កើនសេវាសាធារណៈតាមរយៈការជួយដល់សង្គម (ដូចជា ការទិញអង្ករឧបត្ថម្ភដល់ជនក្រីក្រ) និងការឧបត្ថម្ភដល់អង្គការក្នុង និងក្រៅរដ្ឋាភិបាល។ ក្រៅពីនេះ កម្មវិធីទី២មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រើប្រាស់ដីធ្លី, ធានាចិរភាពបរិស្ថានល្អ, គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងបញ្ជីសារពើភ័ណ្ឌ។ **ឧទាហរណ៍៖** កែលម្អសួនសាធារណៈ ការប្រមូលសំរាម និងការស្តារប្រព័ន្ធប្រឡាយទឹកកខ្វក់។

- ✓ **កម្មវិធីទី៣-លើកកម្ពស់សន្តិសុខនិងសុវត្ថិភាពសាធារណៈ៖** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈក្នុងវិស័យសន្តិសុខសាធារណៈ ដែលជាកម្មវិធីដើម្បីគាំទ្រសន្តិសុខសង្គម និងការទប់ស្កាត់បទល្មើសផ្សេងៗ។ **ឧទាហរណ៍៖** គោលនយោបាយភូមិឃុំមានសុវត្ថិភាព និងគណៈបញ្ជាការឯកភាព។

- ✓ **កម្មវិធីទី៤-ពង្រឹងរដ្ឋបាលទូទៅ៖** មានគោលដៅដើម្បីបង្កើនប្រសិទ្ធភាពលើសេវាគាំទ្រទូទៅ ដែលជាកម្មវិធីដើម្បីបង្កើនប្រសិទ្ធភាពដំណើការរដ្ឋបាល និងការទំនាក់ទំនងលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។ **ឧទាហរណ៍៖** ការពង្រឹងសមត្ថភាពស្ថាប័ន (វគ្គបណ្តុះបណ្តាល, សិក្ខាសាលា, កម្មសិក្សា, ការរៀបចំលិខិតគតិយុត្តិ និងផ្សេងៗ), ការទទួលភ្ញៀវអន្តរជាតិ, ការតាំងពិព័រណ៍, ការឃោសនា និងផ្សព្វផ្សាយ និងផ្សេងៗ។

*បន្ទាប់ពីបង្កើតកម្មវិធីរួច ក្រុមការងារថវិកាត្រូវរៀបចំបង្កើតរចនាសម្ព័ន្ធអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដូចបានបង្ហាញខាងក្រោម។*

### ៣.២.៣ ការបង្កើតអនុកម្មវិធី

ទោះបីជាគោលបំណងគោលនយោបាយមានតែមួយ និងកម្មវិធីមានចំនួន៤ក៏ដោយ ក៏ចំនួនអនុកម្មវិធីមិនមានចំនួនកំណត់ឡើយ។ អនុកម្មវិធីនៅក្រោមកម្មវិធីនីមួយៗ ត្រូវតែឆ្លុះបញ្ចាំងគោលបំណងនៃកម្មវិធី និងត្រូវមានគោលបំណងច្បាស់លាស់ ដើម្បីអាចឱ្យយើងរៀបចំចង្កោមសកម្មភាពបានត្រឹមត្រូវសម្រាប់សម្រេចបានលទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី។ ឧទាហរណ៍នៅតារាងទី៣ខាងក្រោមបង្ហាញអំពីរចនាសម្ព័ន្ធអនុកម្មវិធី។

*តារាងទី៣៖ ឧទាហរណ៍ស្តីពីទំនាក់ទំនងរវាងកម្មវិធី និងអនុកម្មវិធី*

| កម្មវិធី | អនុកម្មវិធី |
|---|---|
| ១.អភិវឌ្ឍវិស័យសេដ្ឋកិច្ច | ១.១ កសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ |
| | ១.២ ពង្រឹងវិស័យកសិកម្ម និងនេសាទ |
| | ១.៣ កែលម្អការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ |

| | |
|---|---|
| | ១.៤ ការអភិវឌ្ឍវិស័យទេសចរណ៍ |
| ២.ពង្រឹងវិស័យសង្គមកិច្ច | ២.១ កិច្ចគាំពារសង្គមដល់ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ |
| | ២.២ ការលើកកម្ពស់ការថែរក្សាបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងគ្រោះមហន្តរាយ |
| | ២.៣ ការអភិវឌ្ឍការអប់រំ, ជំនាញបច្ចេកទេស និងអប់រំកាយនិងកីឡា |
| | ២.៤ ពង្រឹងស្តង់ដារសុខភាព និងអាហារូបត្ថម្ភ |
| | ២.៥ លើកកម្ពស់ការអភិវឌ្ឍយុវជន និងកីឡា |
| ៣. លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ | ៣.១ ពង្រឹងគោលនយោបាយភូមិឃុំមានសុវត្ថិភាព |
| | ៣.២ ពង្រឹងការការពារការជួញដូរមនុស្ស |
| | ៣.៣ កាត់បន្ថយការរត់ពន្ធ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ |
| ៤. ពង្រឹងរដ្ឋបាលទូទៅ | ៤.១ បង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល |
| | ៤.២ សេវាគាំទ្រទូទៅ |

### ៣.២.៤ ការបង្កើតចង្កោមសកម្មភាព

ចង្កោមសកម្មភាព គឺជាបណ្តុំសកម្មភាព ដែលមានគោលបំណងច្បាស់លាស់ ឆ្លើយតបទៅនឹងគោលបំណងរបស់អនុកម្មវិធី។ ដូចបានបង្ហាញក្នុងតារាងទី៤ អនុកម្មវិធី៤.១ស្តីពី*«ការបង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល»* មានចង្កោមសកម្មភាព៤.១.១ ស្តីពី *«ការពង្រឹងសមត្ថភាពស្ថាប័ន»*។ ដើម្បីសម្រេចលទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាពនេះ ត្រូវមានសកម្មភាពលម្អិតមួយចំនួនដូចជា÷ ការរៀបចំវគ្គបណ្តុះបណ្តាល, សិក្ខាសាលា,ប្រជុំ និងកម្មសិក្សា ដូចបានបង្ហាញក្នុងតារាងទី៥ខាងក្រោម។ ដូចនេះ ដើម្បីធានាថាចង្កោមសកម្មភាពមានភាពសមស្រប គួរតែធ្វើការចោទសួរនូវសំណួរមួយចំនួនដូចខាងក្រោម÷

- *ភាពសមស្រប (Appropriateness)*
    - ✓ តើចង្កោមសកម្មភាពនឹងបង្កើតលទ្ធផលក្នុងឆ្នាំ តាមការរំពឹងទុកដែរឬទេ?
    - ✓ តើចង្កោមសកម្មភាពមានភាពចាំបាច់សម្រាប់បង្កើតលទ្ធផលក្នុងឆ្នាំដែរឬទេ?
    - ✓ តើមានចង្កោមសកម្មភាពណាដែលបង្កើតលទ្ធផលក្នុងឆ្នាំដូចគ្នា?
- *លទ្ធភាពដែលអាចអនុវត្តបាន (Feasibility)*
    - ✓ តើចង្កោមសកម្មភាពអាចអនុវត្តបានតាមលក្ខណៈបច្ចេកទេសដែរឬទេ?
    - ✓ តើមានជម្រើសផ្នែកបច្ចេកទេសដែរឬទេ? ប្រសិនបើមាន តើជម្រើសណាមួយដែលល្អ?

- ✓ តើធនធាន ឬហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ អាចប្រើប្រាស់មានប្រសិទ្ធភាពដែរឬទេ? ជាជាងការទិញសម្ភារបរិក្ខារថ្មី ឬសាងសង់អគារថ្មី?

➢ *សមត្ថភាព (Capacity)*

- ✓ តើមានសមត្ថភាពចាំបាច់គ្រប់គ្រាន់រួចហើយឬនៅសម្រាប់អនុវត្តចង្កោមសកម្មភាព ដើម្បីបង្កើតលទ្ធផលក្នុងឆ្នាំដែរឬទេ?
- ✓ ប្រសិនបើបញ្ហាសមត្ថភាពនៅមានកម្រិតហើយគ្មានធនធានបន្ថែម តើគួរចាត់វិធានការបែបណាដើម្បីកែលម្អសមត្ថភាព ?

➢ *លទ្ធផលដែលមិនបានគិតទុកជាមុន (Unintended Results)*

- ✓ តើមានលទ្ធផលជាអវិជ្ជមាន (ឧទាហរណ៍ ការធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន) ដែរឬទេ?
- ✓ ប្រសិនបើមាន តើមានវិធានការអ្វីដើម្បីកាត់បន្ថយលទ្ធផលអវិជ្ជមាននេះដែរឬទេ?

*តារាងទី៤÷ ការរៀបចំចង្កោមសកម្មភាព*

| **ឧទាហរណ៍÷** អនុកម្មវិធី៤.១ស្តីពីការបង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល | ចង្កោមសកម្មភាព |
|---|---|
| | ៤.១.១ ពង្រឹងសមត្ថភាពស្ថាប័ន<br>៤.១.២ រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិ<br>៤.១.៣ ចូលរួម ទំនាក់ទំនងផ្សព្វផ្សាយសាធារណៈ |

### ៣.២.៥ ការបង្កើតសកម្មភាព

សកម្មភាពនីមួយៗ ត្រូវតែមានគោលដៅឆ្ពោះទៅសម្រេចគោលបំណងជាក់លាក់ ដែលនឹងរួមចំណែកសម្រេចគោលបំណងនៃចង្កោមសកម្មភាព។ ដើម្បីធានាថា រាល់សកម្មភាពទាំងអស់ត្រូវបានគ្រោងសម្រាប់អនុវត្ត ហើយការចំណាយសម្រាប់អនុវត្តសកម្មភាពទាំងនោះ ដែលនឹងត្រូវបូកសរុបជាការចំណាយរួមរបស់ចង្កោមសកម្មភាព, អនុកម្មវិធី និងកម្មវិធី គួរតែមើលទៅលើប្រភេទទាំង៤នៃសកម្មភាព ដូចខាងក្រោម÷

❖ *សកម្មភាពវិនិយោគសាធារណៈ*

ជាទូទៅសកម្មភាពវិនិយោគសាធារណៈ ពាក់ព័ន្ធនឹងការទិញទ្រព្យសកម្មរយៈពេលវែង ដូចជា រថយន្ត សម្ភារបរិក្ខារ ឬ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ និងស្ពាន ការផលិតថាមពលអគ្គិសនី ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធធារាសាស្ត្រ។ល។ សកម្មភាពវិនិយោគមានពាក់ព័ន្ធនឹងថ្លៃចំណាយបច្ចុប្បន្ន ដែលត្រូវធ្វើការ

ពិចារណាចាប់តាំងពីដំបូងមកម្ល៉េះ។ **ឧទាហរណ៍**÷ ការសាងសង់ផ្លូវថ្នល់ថ្មី នឹងត្រូវមានការចំណាយថវិកាបន្ថែមសម្រាប់ការថែទាំផ្លូវថ្នល់ ដើម្បីធានាថាផ្លូវថ្នល់ទាំងអស់មានគុណភាពគង់វង្ស ស្របតាមស្តង់ដារគុណភាពដែលតម្រូវ។

❖ *សកម្មភាពសេវាសង្គមកិច្ច និងបរិស្ថាន*

សកម្មភាពនេះពាក់ព័ន្ធនឹងការផ្តល់សេវាអប់រំ, សុខាភិបាល និងផ្សេងៗ ដូចជា សកម្មភាពជួយដល់សង្គម (ដូចជា ការទិញអង្ករឧបត្ថម្ភដល់ជនក្រីក្រ), ការឧបត្ថម្ភដល់អង្គការក្នុង និងក្រៅរដ្ឋាភិបាល និងសកម្មភាពគ្រប់គ្រងការប្រើប្រាស់ដីធ្លី, បរិស្ថាន (កែលម្អសួនសាធារណៈ ការប្រមូលសម្រាម និងការស្តារប្រព័ន្ធប្រឡាយទឹកកខ្វក់), គ្រោះមហន្តរាយ, ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ។

❖ *សកម្មភាពសន្តិសុខ និងសុវត្ថិភាពសាធារណៈ*

សកម្មភាពនេះ ពាក់ព័ន្ធការធ្វើអន្តរាគមន៍ផ្សេងៗ ដូចជា ការលើកកម្ពស់សុវត្ថិភាពភូមិ ឃុំ, ការទប់ស្កាត់ការជួញដូរមនុស្ស, ការកាត់បន្ថយការរត់ពន្ធ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។

❖ *សកម្មភាពរដ្ឋបាល*

ជាទូទៅ សកម្មភាពរដ្ឋបាល គឺជាការងារមានលក្ខណៈជាកិច្ចការគ្រប់គ្រង សម្រាប់គាំទ្រដល់ដំណើរការប្រតិបត្តិការប្រចាំថ្ងៃ។ សកម្មភាពទាំងនេះ គឺជាកិច្ចការរដ្ឋបាលទូទៅរបស់ការិយាល័យ ដែលជាសកម្មភាពប្រចាំថ្ងៃ និងមិនងាយនឹងបែងចែកជាឯកតា និងបរិមាណ ដើម្បីងាយស្រួលក្នុងការរៀបចំផែនការ និងការគណនាថ្លៃចំណាយឡើយ។ នៅក្នុងករណីភាគច្រើន បន្ទុកការងារ ឬកិច្ចការដែលអនុវត្តនៅក្នុងរដ្ឋបាល មានទំនាក់ទំនងទៅនឹងរចនាសម្ព័ន្ធរបស់អង្គភាព។ សកម្មភាពរដ្ឋបាល បែងចែកជា០៣ប្រភេទ÷

១. កិច្ចការជាក់លាក់ ដូចជា ការចុះត្រួតពិនិត្យ និងផ្សេងៗ

២. ដំណើរការដែលអនុវត្តប្រចាំថ្ងៃ ដូចជា÷ ការចូលរួមសិក្ខាសាលា, វគ្គសិក្សា និងទំនាក់ទំនងជាមួយនឹងអង្គភាពប្រតិបត្តិការផ្សេងៗ និង

៣. ការថែទាំអគារ និងសម្ភារបរិក្ខារ។

*តារាងទី៥÷ ការរៀបចំសកម្មភាព*

| **ឧទាហរណ៍**÷ចង្កោមសកម្មភាពទី៤.១.១ស្តីពីការពង្រឹងសមត្ថភាពស្ថាប័ន | សកម្មភាព |
|---|---|
| | ៤.១.១.១ វគ្គបណ្តុះបណ្តាល<br>៤.១.១.២ សិក្ខាសាលា |

| | |
|---|---|
| | ៤.១.១.៣ ប្រជុំ<br>៤.១.១.៤ កម្មសិក្សា |

**៣.៣ ជំហានទី៣-វិធីសាស្ត្រកំណត់គោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព**

*(ជំហានទី ៣ នេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី១.១ ដូចមានជូនភ្ជាប់មកជាមួយ)*

ក្រោយពីបានបង្កើតរចនាសម្ព័ន្ធកម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និងសកម្មភាព ជំហានបន្ទាប់ត្រូវកំណត់ពីគោលបំណងរបស់វា។ ទោះជាយ៉ាងណាក៏ដោយ ពុំចាំបាច់កំណត់ពីគោលបំណងរបស់សកម្មភាពទេ។ ការកំណត់គោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព គឺផ្តើមចេញពីការពិនិត្យទៅលើបញ្ហាប្រឈមដែលត្រូវដោះស្រាយ ហើយទន្ទឹមនោះ យើងក៏ត្រូវយកចិត្តទុកដាក់ផងដែរថា គោលបំណងនោះមានទិសដៅ និងគោលដៅដែលអាចសម្រេចបាន។ ជាឧទាហរណ៍ តារាងទី៦ និង៧ ខាងក្រោមបង្ហាញពីការកំណត់គោលបំណងរបស់កម្មវិធី និងអនុកម្មវិធី។

គួរកត់សំគាល់ថា ការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព គឺត្រូវស្ថិតនៅក្នុងដែនសមត្ថកិច្ច ឬការទទួលខុសត្រូវរបស់រដ្ឋបាលរាជធានី ខេត្ត។ ការធ្វើដូចនេះ មិនត្រឹមតែអាចឱ្យយើងអាចធ្វើការកែលម្អការអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចជួយឱ្យមានទំនុកចិត្តថា កិច្ចការដែលត្រូវបំពេញអាចសម្រេចបានល្អ និងមានការទទួលខុសត្រូវច្បាស់លាស់លើសមិទ្ធកម្ម។

*តារាងទី៦÷ ឧទាហរណ៍គោលបំណងនៃកម្មវិធី*

| កម្មវិធី | គោលបំណង |
|---|---|
| **១. អភិវឌ្ឍវិស័យសេដ្ឋកិច្ច** | កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ |
| **២. ពង្រឹងវិស័យសង្គមកិច្ច** | ពង្រឹងសេវាសាធារណៈ និងលើកកម្ពស់វិស័យកីឡា, អប់រំ, សុខាភិបាល, វប្បធម៌ និងផ្សេងៗ។ ឧបត្ថម្ភដល់អង្គការក្នុង និងក្រៅរដ្ឋាភិបាល។ ធានាចិរភាពបរិស្ថានល្អ, គ្រោះមហន្តរាយ, បម្រែបម្រួលអាកាសធាតុ, ការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ។ |
| ៣. លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ | គាំទ្រសន្តិសុខសង្គម និងគាំទ្រដំណើរការលុបបំបាត់បទល្មើសផ្សេងៗ |

| | |
|---|---|
| ៤. ពង្រឹងរដ្ឋបាលទូទៅ | បង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល និងការទំនាក់ទំនងលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ |

*តារាងទី៧÷ ឧទាហរណ៍គោលបំណងនៃអនុកម្មវិធី*

| ឧទាហរណ៍÷ អនុកម្មវិធី | គោលបំណង |
|---|---|
| **១.១ បង្កើនប្រសិទ្ធភាពដំណើរការរដ្ឋបាល** | ពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈការបណ្តុះបណ្តាល, សិក្ខាសាលា, កម្មសិក្សា, រៀបចំលិខិតគតិយុត្តិ និងផ្សេងៗ |
| **១.២ សេវាគាំទ្រទូទៅ** | ការទទួលភ្ញៀវអន្តរជាតិ, ការតាំងពិព័រណ៍, ការឃោសនា និងផ្សព្វផ្សាយ និងផ្សេងៗ |

គោលបំណងនៃកម្មវិធី និងអនុកម្មវិធី ដូចបានបង្ហាញជាឧទាហរណ៍ក្នុងតារាងទី៦ និងទី៧ខាងលើ គឺជាសារមួយខ្លី តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលបង្ហាញអំពីគោលបំណង និងប្រាប់ពីមូលហេតុថា ហេតុអ្វីបានជាយើងត្រូវបង្កើតកម្មវិធី និងអនុកម្មវិធី។ ម្យ៉ាងទៀត គោលបំណងនោះត្រូវមានទំនាក់ទំនងទៅនឹងលទ្ធផលចុងក្រោយនៃកម្មវិធី និងលទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី និងចង្កោមសកម្មភាព។ ដូចនេះ មានន័យថា រាល់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលបានកំណត់ត្រូវធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងគោលបំណងនៃលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ។

បន្ទាប់ពីការកំណត់គោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរួចហើយ យើងអាចធ្វើការពិនិត្យឡើងវិញអំពីភាពសមស្រប ដោយលើកជាសំណួរមួយចំនួនដូចខាងក្រោម ÷

- ✓ តើកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពបង្កើតឡើងមានភាពច្បាស់លាស់ឬទេ?
- ✓ តើគោលបំណងនៃកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពបានឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលឬទេ?
- ✓ តើយើងអាចបង្កើតសូចនាករសមិទ្ធកម្មគន្លឹះ (KPI) សម្រាប់វាស់វែងគោលបំណងកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពបានដែរឬទេ? (ការធ្វើដូច្នេះ គឺដើម្បីដឹងថានៅពេលណាយើងនឹងសម្រេចបានតាមគោលបំណងនោះ)
- ✓ តើគោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពមានទំនាក់ទំនងនឹងគ្នាឬទេ? ហើយតើគោលបំណងទាំងនេះមានទំនាក់ទំនងទៅនឹងលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំដែរ

ឬទេ? ហើយតើគោលបំណងនៃចង្កោមសកម្មភាពគាំទ្រគោលបំណងនៃអនុកម្មវិធី និងគោលបំណងនៃអនុកម្មវិធីគាំទ្រដល់គោលបំណងនៃកម្មវិធីដែរឬទេ?

### ៣.៤ ជំហានទី ៤- វិធីសាស្ត្រក្នុងការកំណត់ខ្សែសង្វាក់លទ្ធផល

*(ជំហានទី ៤ នេះ បានផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី ១.២ និង១.៣ ដូចមានជូនភ្ជាប់មកជាមួយ)*

បន្ទាប់ពីបានរៀបចំរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព និងកំណត់គោល-បំណងរបស់វារួចមក ជំហានបន្ទាប់ គឺការសាងទិន្នន័យសម្រាប់ខ្សែសង្វាក់លទ្ធផល ដែលជា « ***ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករសមិទ្ធកម្មនៃលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំ***»។ ដ្យាក្រាមទី១ បង្ហាញអំពីដំណើរការពីលើចុះក្រោម/ពីក្រោមឡើងលើនៃខ្សែសង្វាក់លទ្ធផល។ ហើយដ្យាក្រាមទី២ បង្ហាញអំពីឋានានុក្រម និងឡូជីកនៃខ្សែសង្វាក់លទ្ធផលរបស់កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព។ ជារួម សូចនាករ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ (Outcome)គឺសម្រាប់កម្រិតកម្មវិធី រីឯសូចនាករ និងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ (Output) គឺសម្រាប់កម្រិតអនុកម្មវិធី និងចង្កោមសកម្មភាព។

ដ្យាក្រាមទី១÷ ខ្សែសង្វាក់លទ្ធផល



ដ្យាក្រាមទី២÷ ឋានានុក្រម និងឡូជីកនៃខ្សែសង្វាក់លទ្ធផល




សម្គាល់÷

-1 KPI/POC ១សូចនាករសមិទ្ធកម្មគន្លឹះក្នុង១លទ្ធផលចុងក្រោយនៃកម្មវិធី (Outcome)

-4 KPIs/SPOP ៤សូចនាករសមិទ្ធកម្មគន្លឹះក្នុង១លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី (cost, quantity, quality, time)

-1 KPI/ACOP ១សូចនាករសមិទ្ធកម្មគន្លឹះក្នុង១លទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាព (operations tracks)

-2 KPIs/AC ២សូចនាករសមិទ្ធកម្មគន្លឹះក្នុង១សកម្មភាព (financial and physical progress)

*តារាងទី ៨: ឧទាហរណ៍ស្តីពីឋានានុក្រមនៃខ្សែសង្វាក់លទ្ធផល*

| ពាក្យ | អត្ថន័យ | ឧទាហរណ៍ |
|---|---|---|
| លទ្ធផលចុងក្រោយ (Outcome) | លទ្ធផលដែលទទួលបានពីការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ | ចំនួនមន្ត្រីដែលបានយកបច្ចេកទេសថ្មីមកអនុវត្ត បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល |
| លទ្ធផលក្នុងឆ្នាំ (Output) | ទំនិញ និងសេវាដែលបានមកពីការអនុវត្តចង្កោមសកម្មភាព និងសកម្មភាព | ចំនួនវគ្គបណ្តុះបណ្តាល, ចំនួនមន្ត្រីដែលទទួលបានការបណ្តុះបណ្តាលវគ្គបច្ចេកទេសថ្មី |
| សកម្មភាព (Activities) | សកម្មភាពដែលមានគោលបំណងច្បាស់លាស់នៅក្នុងចង្កោមសកម្មភាព | ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំ កម្មសិក្សា និងផ្សេងៗ |

### ៣.៤.១ ការកំណត់លទ្ធផលចុងក្រោយនៃកម្មវិធី

*(ចំណុច ៣.៤.១ មានសារសំខាន់សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី១.៣ ជួរឈរទី ៥)*

នៅពេលកម្មវិធី និងអនុកម្មវិធីបានផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងគោលបំណងគោលនយោបាយជំហានបន្ទាប់ គឺត្រូវកំណត់លទ្ធផលចុងក្រោយ (Outcome) ដែលកម្មវិធីត្រូវបានបង្កើតឡើងដើម្បីសម្រេចឱ្យបាន។ លទ្ធផលចុងក្រោយ (Outcome) ត្រូវកំណត់យ៉ាងណា ដើម្បីអាចវាស់វែងបាន (Measurable Result) និងធានាថាគោលបំណងនៃកម្មវិធីអាចសម្រេចបានតាមការគ្រោងទុក។ កម្មវិធីនីមួយៗ ត្រូវមានលទ្ធផលចុងក្រោយយ៉ាងតិចមួយ។

ការកំណត់លទ្ធផលចុងក្រោយត្រូវពិចារណាលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម ÷

- ✓ ឆ្លុះបញ្ចាំងពីគោលបំណងច្បាស់លាស់នៃកម្មវិធី
- ✓ ឆ្លុះបញ្ចាំងពីលទ្ធផលដែលកម្មវិធីចង់បាន
- ✓ មានសូចនាករ ដែលអាចធ្វើការតាមដាន និងវាយតម្លៃលទ្ធផលបាន
- ✓ ត្រូវកំណត់ឱ្យបានច្បាស់ចំពោះអ្នកដែលត្រូវទទួលផលពីការអនុវត្តកម្មវិធី និង
- ✓ លទ្ធផលចុងក្រោយ ត្រូវមានការពិគ្រោះយោបល់ឲ្យបានទូលាយ ដើម្បីជៀសវាងការលើកកម្មវិធីត្រួតគ្នា និងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការបែងចែកមុខងារនិងភារកិច្ចរវាងភាគីពាក់ព័ន្ធ។

**ឧទាហរណ៍ទី១÷** ***កម្មវិធីទី១-អភិវឌ្ឍវិស័យសេដ្ឋកិច្ច*** មានអនុកម្មវិធីស្តីពី ***ការពង្រឹងវិស័យកសិកម្ម និងនេសាទ***។ ការបង្កើនផលិតភាពកសិកម្មតាមរយៈសេវាប្រពលវប្បកម្មកាន់តែរឹងមាំ និងលំហូរនៃបច្ចេកវិទ្យាជាំដុះ

ថ្មីអាចជួយជំរុញកំណើនវិស័យកសិកម្ម និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ព្រោះវាបានលើកទឹកចិត្តដល់ប្រជាកសិករ ដែលមានស្រាប់នៅក្នុងវិស័យនេះឱ្យបង្កើនផលិតភាព និងជំរុញឱ្យមានវិនិយោគិនថ្មីបើកអាជីវកម្មកសិធុរកិច្ច បង្កើតការងារ បង្កើនប្រាក់ចំណូល និងបង្កើនការប្រមូលពន្ធ។

ជាទូទៅ ផលវិបាកក្នុងការកំណត់លទ្ធផលចុងក្រោយនៃកម្មវិធី គឺការធានាថាលទ្ធផលចុងក្រោយអាចវាស់វែងបាន និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត។ ការបង្កើនផលិតភាពកសិកម្មដែលបានបង្ហាញខាងលើ អាចសម្រេចគោលបំណងនៃលទ្ធផលចុងក្រោយ និងអាចវាស់វែងផលិតភាពកសិកម្មបាន។ ប៉ុន្តែលទ្ធផល ដែលអាចមានផ្សេងទៀត គឺហួសពីសមត្ថភាពគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ជាពិសេសការលើកទឹកចិត្តឱ្យមានវិនិយោគិនថ្មីចាប់ផ្តើមបើកអាជីវកម្មកសិធុរកិច្ច ដែលនឹងបង្កើតការងារ បង្កើនប្រាក់ចំណូល និងបង្កើនការប្រមូលពន្ធ។ អាស្រ័យហេតុនេះ ពេលកំណត់លទ្ធផលចុងក្រោយនៃកម្មវិធី ចាំបាច់ត្រូវធានាថាលទ្ធផលចុងក្រោយ គឺស្ថិតនៅក្នុងវិសាលភាពនៃការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តក្នុងគោលបំណងធានាគណនេយ្យភាពសម្រាប់សមិទ្ធកម្ម។ ទោះជាយ៉ាងណាក៏ដោយ អាកាសធាតុមិនអំណោយផល ដែលមិនអាចប៉ាន់ស្មានដឹងមុន និងឥរិយាបថផ្លាស់ប្តូររបស់កសិករ ក៏អាចប៉ះពាល់ដល់ការសម្រេចលើកម្មវិធីផងដែរ។

**ឧទាហរណ៍ទី២÷** *ការបញ្ចប់ការសាងសង់ផ្លូវថ្មី គឺជាលទ្ធផលសម្រេចបាន។* អត្ថប្រយោជន៍ទទួលបានពីផ្លូវនេះ គឺការរួមចំណែកដល់ការកាត់បន្ថយថ្លៃចំណាយលើការថែទាំរថយន្ត, កាត់បន្ថយពេលវេលាធ្វើដំណើរ ដែលធ្វើឱ្យកសិករងាយស្រួលក្នុងការដឹកជញ្ជូនផលិតផលទៅទីផ្សារ ដែលនេះជាការរួមចំណែករបស់វិស័យកសិកម្មដល់កំណើនសេដ្ឋកិច្ច។ ក្រៅពីនេះ អត្ថប្រយោជន៍ពីវិស័យកសិកម្មក៏ពឹងផ្អែកយ៉ាងខ្លាំងទៅលើកត្តាផ្សេងទៀត មានដូចជា÷ ផលិតភាពកសិកម្ម, គ្រាប់ពូជ និងអាកាសធាតុ។ ទោះជាយ៉ាងនេះក្តី ការសិក្សាលើកត្តាទាំងនេះមានការលំបាកខ្លាំងដោយសារត្រូវចំណាយធនធានច្រើន និងមិនអាចធ្វើការវាយតម្លៃបានញឹកញាប់ និងជារៀងរាល់ប្រាំឆ្នាំឡើយ។

ដូចនេះ ដើម្បីសម្រេចគោលបំណងនៃលទ្ធផលចុងក្រោយ (Outcome) ចាំបាច់ត្រូវធានាថា ការកំណត់លទ្ធផលចុងក្រោយមានភាពប្រាកដប្រជា ដើម្បីអាចឱ្យកម្មវិធីនេះរួមចំណែកដល់ការសម្រេចនូវគោលបំណងគោលនយោបាយ។ ផ្អែកលើឧទាហរណ៍ខាងលើ លទ្ធផលចុងក្រោយ (Outcome) ដែលរួមមាន÷

- ✓ ការបង្កើនការរួមចំណែករបស់វិស័យកសិកម្មរបស់រដ្ឋបាលខេត្តនៅក្នុងផ.ស.ស
- ✓ ការកាត់បន្ថយម៉ោងធ្វើដំណើរ និង
- ✓ ការកាត់បន្ថយថ្លៃចំណាយលើការថែទាំរថយន្ត។

ទោះបីជាកម្មវិធីមានលទ្ធផលចុងក្រោយចំនួនបីយ៉ាងណាក៏ដោយ ក៏មានលទ្ធផលមួយដែលរដ្ឋបាលរាជធានី ខេត្តមានលទ្ធភាពងាយស្រួលក្នុងការវាស់វែង គឺ «*ការកាត់បន្ថយពេលវេលាធ្វើដំណើរ*»។

### ៣.៤.២ ការកំណត់លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី និងចង្កោមសកម្មភាព

*(ចំណុច ៣.៤.២ នេះមានសារសំខាន់សម្រាប់បំពេញតារាងឧបសម្ព័ន្ធទី១.២ ជួរឈរទី២ និងតារាងទី១.៣ ជួរឈរទី៣)*

លទ្ធផលក្នុងឆ្នាំ (Output) គឺជាលទ្ធផលអាចវាស់បានក្នុងឆ្នាំ ដែលអាចឈានទៅសម្រេចបានលទ្ធផលចុងក្រោយ និងឈានទៅសម្រេចគោលបំណងនៃកម្មវិធីដែលចង់បាន។ លទ្ធផលក្នុងឆ្នាំ (Output) គឺសំដៅដល់សេវា និងទំនិញ ដូចជា ផ្លូវ សួនច្បារ អគារ ល្ង ។ល។ ដែលទទួលបានពីសកម្មភាព ឬដំណើរការអ្វីមួយ។ លទ្ធផលក្នុងឆ្នាំ (Output) មានពីរកម្រិតគឺ កម្រិតអនុកម្មវិធី និងចង្កោមសកម្មភាព។ ដូចនេះ ការសម្រេចបានលទ្ធផលក្នុងឆ្នាំ (Output)នៃអនុកម្មវិធី នឹងឈានទៅសម្រេចបានលទ្ធផលចុងក្រោយ (Outcome)នៃកម្មវិធី និងគោលបំណងគោលនយោបាយ (Policy Objective)។ ចំណែក ការសម្រេចបានលទ្ធផលក្នុងឆ្នាំ (Output) នៃចង្កោមសកម្មភាព នឹងឈានទៅសម្រេចបានលទ្ធផលក្នុងឆ្នាំ (Output)នៃអនុកម្មវិធី និងលទ្ធផលចុងក្រោយ (Outcome)នៃកម្មវិធី។

**ឧទាហរណ៍÷** នៅក្នុងដំណើរការកសាងផ្លូវថ្នល់ មានសកម្មភាព ដូចជា ការប្រមូលកាកសំណល់រឹង ការថែទាំសួនច្បារសាធារណៈ ការដាក់ភ្លើងបំភ្លឺផ្លូវ ការពង្រឹងសុវត្ថិភាពផ្លូវថ្នល់ និងផ្សេងៗ ដើម្បីសម្រេចលទ្ធផលចុងក្រោយនៃកម្មវិធីគឺ ***«ផ្លូវថ្នល់»***។

រដ្ឋបាលរាជធានី ខេត្ត ត្រូវបង្កើតលទ្ធផលក្នុងឆ្នាំ (Output)របស់ខ្លួន ដោយធ្វើការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធ។ ដោយសារលទ្ធផលក្នុងឆ្នាំទាំងអស់ត្រូវរួមចំណែកដល់ការបង្កើតលទ្ធផលចុងក្រោយជាក់លាក់ណាមួយ ដើម្បីសម្រេចបានគោលបំណងរបស់កម្មវិធី ដូច្នេះ ការកំណត់លទ្ធផលក្នុងឆ្នាំ (Output) ត្រូវពិចារណាលើលក្ខណៈសម្បត្តិមួយចំនួន ដូចខាងក្រោម÷

- ✓ ត្រូវស្ថិតនៅក្នុងវិសាលភាពគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្ត ទោះជាការអនុវត្តដោយផ្ទាល់ ឬជាកិច្ចសន្យាជាមួយនឹងភាគីខាងក្រៅក៏ដោយ
- ✓ ចំនួនអ្នកដែលត្រូវទទួលផលពីការផ្តល់ទំនិញ និងសេវា
- ✓ ត្រូវតែអាចវាស់វែងបាន ពាក់ព័ន្ធនឹងថ្លៃ *ចំណាយ, បរិមាណ, គុណភាព និងពេលវេលា*
- ✓ ត្រូវមានភាពជាក់លាក់ ច្បាស់លាស់ ដើម្បីងាយស្រួលកំណត់អ្នកទទួលខុសត្រូវ និងគ្រប់គ្រង
- ✓ ត្រូវមានភាពច្បាស់លាស់អំពីថវិកា ដែលត្រូវចំណាយ និងលទ្ធផលទទួលមកវិញ។

**៣.៥ ជំហានទី ៥- ពិនិត្យឡើងវិញលើឡូជីក (Logic) នៃការកសាងរចនាសម្ព័ន្ធកម្មវិធី**

*(ជំហានទី ៥ នេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញនៅក្នុងតារាងឧបសម្ព័ន្ធទី ១.១, ១.២ និង១.៣ ដូចមានជូនភ្ជាប់មកជាមួយ)*

ជាក់ស្តែងការកសាងថវិកាកម្មវិធី គឺជាដំណើរការមួយដែលទាមទារនូវការពិនិត្យសារចុះសារឡើង ដើម្បីធានាសង្គតិភាពនៃការរៀបចំកម្មវិធី ជាពិសេស ឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយដែលបានដាក់ចេញ។ រចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលបានរៀបចំរួច តម្រូវឱ្យក្រុមការងារថវិកាត្រូវពិនិត្យសារចុះសារឡើង ដើម្បីធ្វើយ៉ាងណាឱ្យមានលក្ខណៈសម្បត្តិដូចខាងក្រោម÷

- ✓ ត្រូវរំលេចឱ្យឃើញអំពីគោលដៅចំបងៗរបស់រដ្ឋបាលរាជធានី ខេត្ត។ ដោយផ្អែកលើគោលដៅដែលបានកំណត់ រដ្ឋបាលរាជធានី ខេត្តត្រូវបង្កើតរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដើម្បីអាចធានាបាននូវគណនេយ្យភាពច្បាស់លាស់។
- ✓ ត្រូវមានការគិតគូជាចំបងលើគោលនយោបាយ និងវិស័យអាទិភាពថ្មីៗដែលរាជរដ្ឋាភិបាលបានដាក់ចេញ (ប្រសិនបើមាន) ដើម្បីរក្សានូវសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា ដែលបានរៀបចំ និងជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំថ្នាក់ក្រោមជាតិ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលថ្នាក់ក្រោមជាតិ។
- ✓ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចមានវិស័យអាទិភាព ដែលត្រូវអនុវត្តខុសៗគ្នា ទោះបីជាត្រូវមានគោលបំណងគោលនយោបាយចំនួនមួយ (១) និងកម្មវិធីចំនួនបួន (៤)ក៏ដោយ ក៏រដ្ឋបាលរាជធានី ខេត្តនីមួយៗនៅតែអាចរៀបចំរចនាសម្ព័ន្ធអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពឱ្យស្របទៅតាមវិស័យអាទិភាពរៀងៗខ្លួន។
- ✓ រចនាសម្ព័ន្ធកម្មវិធី រួមមានកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ✓ ចំពោះឈ្មោះនៃអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ត្រូវមានលក្ខណៈជាការពិពណ៌នា (Descriptive) ពីបញ្ហាចង់ដោះស្រាយ។ រីឯគោលបំណងនៃកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ត្រូវមានលក្ខណៈច្បាស់លាស់ ព្រោះត្រូវឆ្លើយតបទៅនឹងបេសកកម្ម និងគោលបំណងគោលនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣.៦ ជំហានទី៦- ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ** (KPI)

*(ជំហានទី ៦ នេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ដើម្បីអាចបំពេញព័ត៌មាននៅក្នុងតារាងឧបសម្ព័ន្ធទី ១.២ និង ១.៣ ដូចមានភ្ជាប់ជូនមកជាមួយ)*

ដើម្បីបង្កើតរចនាសម្ព័ន្ធកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលអាចផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងលទ្ធផលចុងក្រោយ (Outcome) និងលទ្ធផលក្នុងឆ្នាំ (Output)បាន គឺចាំបាច់បំផុតត្រូវកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) និងគោលដៅសូចនាករសមិទ្ធកម្មគន្លឹះ (KPI Target) ដើម្បីឱ្យសមិទ្ធកម្មដែលបានគ្រោងទុកអាចវាស់វែងបាន ដោយធៀបជាមួយនឹងសមិទ្ធកម្មជាក់ស្តែង ដូចមានបង្ហាញក្នុងតារាងទី៩ខាងក្រោម។

❖ *ឋានានុក្រមនៃសូចនាករសមិទ្ធកម្មគន្លឹះ*

សម្រាប់ការរៀបចំថវិកាកម្មវិធី ពុំចាំបាច់កំណត់ KPI សម្រាប់គោលបំណងគោលនយោបាយនោះទេ ដោយសារតែគោលបំណងគោលនយោបាយត្រូវតែកំណត់ និងវាស់វែងនៅថ្នាក់ជាតិ។ ការរៀបចំថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត ចាំបាច់ត្រូវតែកំណត់ KPI សម្រាប់លទ្ធផលចុងក្រោយនៃកម្មវិធី, លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី និងចង្កោមសកម្មភាព និងសម្រាប់សកម្មភាព។ ឋានានុក្រមនៃសូចនាករសមិទ្ធកម្មគន្លឹះ(KPI) បានបង្ហាញក្នុងតារាងទី៩ខាងក្រោម÷

*តារាងទី៩÷ ឋានានុក្រមសូចនាករសមិទ្ធកម្មគន្លឹះ*

| គោលដៅ | ចំនួនសូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|
| - លទ្ធផលចុងក្រោយនៃកម្មវិធី | KPI មួយ (១) ដែលត្រូវវាស់វែងសមិទ្ធកម្ម (Performance) |
| - លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធី | KPI បួន (៤) ដែលត្រូវវាស់វែងបរិមាណ (Quantity), គុណភាព (Quality), ពេលវេលា (Time) និងថ្លៃចំណាយ (Cost) |
| - លទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាព | KPI មួយ (១) ដែលត្រូវវាស់វែងវឌ្ឍនភាពនៃការអនុវត្ត (Operations Tracks) |
| - សកម្មភាព | KPI ពីរ (២) ដែលត្រូវវាស់វែងវឌ្ឍនភាពជារូបវន្ត (Physical) និងជាហិរញ្ញវត្ថុ (Finance) |

❖ *ចរិតលក្ខណៈនៃសូចនាករសមិទ្ធកម្មគន្លឹះ*

សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវមានលក្ខណៈ SMART (ច្បាស់លាស់, វាស់វែងបាន, អាចសម្រេចបាន, ពាក់ព័ន្ធ និងពេលវេលាកំណត់) ដូចអត្ថន័យខាងក្រោម÷

- ✓ **ច្បាស់លាស់ (Specific)**÷ ធានាថាលទ្ធផលសម្រាប់ដោះស្រាយបញ្ហាប្រឈមមានការទទួលខុសត្រូវ មានអ្នកទទួលផលប្រយោជន៍ និងនិរន្តរភាពបន្ទាប់ពីបញ្ចប់។
- ✓ **វាស់វែងបាន (Measurable)**÷ មានលទ្ធភាពអាចវាស់វែងបាន, មានព័ត៌មាន និងទិន្នន័យដែលត្រូវការ។
- ✓ **អាចសម្រេចបាន (Attainable)**÷ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចលទ្ធផលចុងក្រោយទៅតាមធនធាន, ពេលវេលា និងគុណភាព។
- ✓ **ពាក់ព័ន្ធ (Relevant)**÷ អាចរៀបចំផែនការប្រតិបត្តិ ផែនការថវិកា និងសកម្មភាពលម្អិត។
- ✓ **ពេលវេលាកំណត់ (Timeframe)**÷ មានពេលវេលាចាប់ផ្តើម និងបញ្ចប់ច្បាស់លាស់។

សូចនាករសមិទ្ធកម្មគន្លឹះ (KPI) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់គោលដៅសម្រាប់ការវាស់វែង (បរិមាណ) ឬការវិនិច្ឆ័យ (គុណភាព) នូវលទ្ធផលដែលសម្រេចបាន។ សូចនាករមានចំនួនកាន់តែតិចគឺកាន់តែល្អ ពីព្រោះការវាស់វែងការប្រែប្រួល (រួមទាំង ការប្រមូល និងការវិភាគទិន្នន័យ) ត្រូវការចំណាយពេលវេលា និងថវិកា។ ទោះជាយ៉ាងនេះក្តី ចាំបាច់ត្រូវតែមានសូចនាករគ្រប់ចំនួន ដើម្បីវាស់វែងកម្រិតផ្លាស់ប្តូរ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី៩ខាងលើ មានសូចនាករសមិទ្ធកម្មគន្លឹះចំនួន៨សម្រាប់វាស់វែង ដូចជានៅកម្រិតលទ្ធផលចុងក្រោយនៃកម្មវិធីចំនួន១ (លទ្ធផលឬសមិទ្ធកម្ម), លទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធីចំនួន៤ (បរិមាណ,គុណភាព, ពេលវេលា និងថ្លៃចំណាយ), លទ្ធផលក្នុងឆ្នាំនៃចង្កោមសកម្មភាពចំនួន១ (វឌ្ឍនភាពនៃការអនុវត្ត ដែលសំដៅដល់សេវាត្រូវបានផ្តល់តាមការគ្រោងទុក) និងនៅកម្រិតសកម្មភាពចំនួន២ (វឌ្ឍនភាពជារូបវន្ត និងជាហិរញ្ញវត្ថុ)។

❖ ***សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលចុងក្រោយ***

***(ចំណុចនេះផ្តល់នូវគំនិត និង សេចក្តីពន្យល់ ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ១.៣ ជួរឈរទី ៥)***

សូចនាករលទ្ធផលចុងក្រោយ (Outcome) គឺជារង្វាស់ ដែលអាចកំណត់គោលដៅសមិទ្ធកម្មចុងក្រោយដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធីក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ ដូចបានបង្ហាញក្នុងតារាងទី១០ លទ្ធផលចុងក្រោយនៃកម្មវិធី ត្រូវបានវាស់វែងដោយ KPI លើសមិទ្ធកម្ម (Performance) ដែលសម្រេចបាន។

**ឧទាហរណ៍**÷ សូចនាករទាំងនេះ រួមមាន÷

- ✓ សិស្សបញ្ចប់ការសិក្សាកាន់តែមានគុណភាពល្អប្រសើរ
- ✓ ការកើនឡើងផលិតភាពកសិកម្ម

- ✓ ការថយចុះអត្រាមរណភាពដោយសារតែជំងឺឆ្លង និង
- ✓ ការកើនឡើងលទ្ធភាពទទួលបានទឹកស្អាតបរិភោគ។

ដើម្បីសម្រេចបានសូចនាករលទ្ធផលចុងក្រោយ (Outcome) នៃកម្មវិធី ត្រូវមានការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ (Output) នៃអនុកម្មវិធីមួយចំនួន។ តារាងទី១០ ខាងក្រោមបង្ហាញអំពីការកំណត់សូចនាករលទ្ធផលចុងក្រោយនៃកម្មវិធីទាំងបួនដូចខាងក្រោម។

*តារាងទី១០÷ ឧទាហរណ៍ការកំណត់សូចនាករលទ្ធផលចុងក្រោយ (Outcome)*

| **កម្មវិធី** | **សូចនាករលទ្ធផលចុងក្រោយ (Outcome) នៃកម្មវិធី** | **ការវាយតម្លៃលើភាពគ្រប់គ្រាន់របស់សូចនាករ** |
|---|---|---|
| **កម្មវិធីទី១-** អភិវឌ្ឍវិស័យសេដ្ឋកិច្ច | ប្រជាជនដែលមានជីវភាពប្រសើរជាងមុន | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |
| **កម្មវិធីទី២-** ពង្រឹងវិស័យសង្គមកិច្ច | សេវាសាធារណៈដែលបានផ្តល់ដល់ប្រជាជនត្រូវបានលើកកម្ពស់ និងមានប្រសិទ្ធភាពជាងមុន | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |
| **កម្មវិធីទី៣-** លើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសាធារណៈ | ប្រជាជនរស់នៅក្នុងមូលដ្ឋានដែលមានសុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អប្រសើរ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |
| **កម្មវិធីទី៤-** ពង្រឹងរដ្ឋបាលទូទៅ | អភិបាលកិច្ចល្អ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ និងជាក់លាក់ |

- ❖ *សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលក្នុងឆ្នាំ*

*(ចំណុចនេះផ្តល់នូវគំនិត និងសេចក្តីពន្យល់ដើម្បីបំពេញព័ត៌មានក្នុងតារាងឧបសម្ព័ន្ធទី ១.២ ជួរឈរទី ២,៣,៤,៥, និង៦ និងតារាងឧបសម្ព័ន្ធទី១.៣ ជួរឈរទី៣ និង៤។)*

**សូចនាករលទ្ធផលក្នុងឆ្នាំ** (Output) គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មនៃការអនុវត្តក្នុងរយៈពេលជាក់លាក់មួយ (មិនលើសពីមួយឆ្នាំ)។

**ឧទាហរណ៍÷**

- ចំនួនមន្ត្រីទទួលបានការបណ្តុះបណ្តាលជំនាញថ្មី
- ចំនួនផ្លូវ ឬ លូទឹក ដែលបានសាងសង់ទៅតាមស្តង់ដារ និង គុណភាព
- ចំនួនអ្នកប្រជាជនដែលទទួលផ្លូវ ឬ សួនច្បារសាធារណៈ

តារាងទី១១ ខាងក្រោមជាឧទាហរណ៍បង្ហាញពីសូចនាករលទ្ធផលក្នុងឆ្នាំនៃអនុកម្មវិធីមួយចំនួន។

*តារាងទី១១÷ ឧទាហរណ៍ការកំណត់សូចនាករលទ្ធផលក្នុងឆ្នាំ*

| **កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព** | **សូចនាករលទ្ធផលក្នុងឆ្នាំ** (Output) | **ការវាយតម្លៃលើភាពគ្រប់គ្រាន់របស់សូចនាករ** |
|---|---|---|
| **កម្មវិធីទី១-អភិវឌ្ឍវិស័យសេដ្ឋកិច្ច** | | |
| **អនុកម្មវិធីទី១.១-** កសាង និង ថែទាំហេដ្ឋារចនាសម្ព័ន្ធ | **សូចនាករទី ១ :** ប្រវែងផ្លូវប្រភេទ DBST និង AC ដែលបានសាងសង់រួច | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី២:** ប្រវែងផ្លូវប្រភេទ AC ដែលបានជួសជុលរួច | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី ៣:** ប្រវែងប្រព័ន្ធលូតាមផ្លូវក្នុងក្រុង | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី ៤:** ផ្ទៃក្រឡាសួនសាធារណៈដែលបានសាងសង់ ឬកែលម្អ | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| **អនុកម្មវិធីទី១.២-** ពង្រឹងវិស័យកសិកម្ម និងនេសាទ | **សូចនាករទី១:** ប្រវែងប្រឡាយដែលបានសាងសង់ | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |
| | **សូចនាករទី២:** ប្រវែងប្រឡាយដែលបានជួសជុល | អាចប្រមូលទិន្នន័យបាន គ្រប់គ្រាន់ និងជាក់លាក់ |

នៅក្នុងការរៀបចំថវិកាកម្មវិធីរបស់រដ្ឋបាលរាជធានី ខេត្ត សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាស់វែងលទ្ធផលក្នុងឆ្នាំ មាន០២(ពីរ)កម្រិត គឺអនុកម្មវិធី និងចង្កោមសកម្មភាព ដូចខាងក្រោម÷

✓ *ទី១- សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលក្នុងឆ្នាំសម្រាប់អនុកម្មវិធី*

សូចនាករសមិទ្ធកម្មគន្លឹះ (KIP) សម្រាប់វាស់វែងលទ្ធផលក្នុងឆ្នាំ (Output)នៃអនុកម្មវិធី មានចំនួន ០៤ គឺបរិមាណ, គុណភាព, ពេលវេលាកំណត់ និងថ្លៃចំណាយ។

**ឧទាហរណ៍÷** សូចនាករវាស់វែងអនុកម្មវិធីស្តីពីការដំឡើងបង្គោលភ្លើងបំភ្លឺផ្លូវ ដូចខាងក្រោម÷

- ✓ ចំនួន (បរិមាណ) បង្គោលភ្លើងបំភ្លឺផ្លូវដែលបានដំឡើងរួច
- ✓ គុណភាព (%) នៃបង្គោលភ្លើងបំភ្លឺផ្លូវដែលបានដំឡើងរួច និងបានត្រួតពិនិត្យរួច
- ✓ ពេលវេលា (%) នៃបង្គោលភ្លើងតាមដងផ្លូវដែលបានដំឡើងតាមផែនការ
- ✓ ភាគរយ (%) នៃថវិកាដែលបានចំណាយ

ដូចបានបង្ហាញជាឧទាហរណ៍ក្នុងតារាងទី១២ខាងក្រោម ការប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ដើម្បីវាស់វែងការប្រែប្រួលរវាងគោលដៅសូចនាករសមិទ្ធកម្មគន្លឹះ (KPI Target) (សមិទ្ធកម្មដែលបានគ្រោង) និងសមិទ្ធកម្មជាក់ស្តែង។ ការប្រើប្រាស់វិធីសាស្ត្រវិភាគលើការប្រែប្រួលនេះ បានផ្តល់ជាមូលដ្ឋានសម្រាប់ជាអនុសាសន៍ក្នុងការផ្តល់ថវិកា ដែលជាមូលដ្ឋានសម្រាប់ការប្រើប្រាស់ថវិកាព័ត៌មានសមិទ្ធកម្មនាពេលអនាគត។

*តារាងទី១២- ឧទាហរណ៍លទ្ធផលក្នុងឆ្នាំ (Output)- ការដំឡើងអំពូលភ្លើងបំភ្លឺផ្លូវថ្នល់ក្នុងភូមិ*

| **សូចនាករសមិទ្ធកម្មគន្លឹះ** | **គោលដៅ សូចនាករសមិទ្ធកម្ម គន្លឹះឆ្នាំ២០២០** | **សមិទ្ធកម្ម ជាក់ស្តែង ឆ្នាំ២០២០** | **ការប្រែប្រួល%** |
|---|---|---|---|
| *បរិមាណ*<br>ចំនួនអ្នកទទួលផលសរុប | ១២៥០ | ៩៥៦ | -២៣% |
| *គុណភាព*<br>បង្គោលភ្លើងសម្រាប់បំពាក់អំពូលបំភ្លឺផ្លូវថ្នល់ថ្មីដែលបានដាក់ពិន្ទុថាពេញចិត្តដោយអធិការកិច្ច | ១២០ | ៩៨ | -១៨% |
| *ពេលវេលាកំណត់*<br>បង្គោលភ្លើងសម្រាប់បំពាក់អំពូលបំភ្លឺផ្លូវថ្នល់ថ្មីដែលបានដំឡើងដោយស្របតាមកាលវិភាគអនុវត្តដែលបានកំណត់ជាមុន | ១២០ | ៩៨ | -១៨% |

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅ សូចនាករសមិទ្ធកម្ម គន្លឹះឆ្នាំ២០២០ | សមិទ្ធកម្ម ជាក់ស្តែង ឆ្នាំ២០២០ | ការប្រែប្រួល% |
|---|---|---|---|
| *ថ្លៃចំណាយ*<br>ថ្លៃចំណាយសរុបលើលទ្ធផលក្នុងឆ្នាំគិតជាលានរៀល | ៥,៨៥០ | ៤,៦៩២ | -១៩% |

*ការវាស់វែងលទ្ធផលក្នុងឆ្នាំ÷*

១. លទ្ធផលក្នុងឆ្នាំបង្ហាញសមិទ្ធកម្មអ្នកទទួលផលពីការផ្គត់ផ្គង់ថាមពលបំភ្លឺផ្លូវថ្នល់ ទោះបីជាចំនួនអ្នកទទួលផលជាក់ស្តែងមានចំនួនតិចជាងគោលដៅក៏ដោយ។

២. ទាំងសូចនាករគុណភាព និងសូចនាករបរិមាណជាក់ស្តែង គឺទាបជាងគោលដៅ។ ការដំឡើងបង្គោលភ្លើងមានការយឺតយ៉ាវជាងកាលកំណត់ ដោយសារតែបញ្ហាអាកាសធាតុដែលធ្វើឱ្យរំខានដល់ការដំឡើង ដែលជាហេតុធ្វើឱ្យមិនអាចសម្រេចគោលដៅជាបរិមាណបាន និងនាំឱ្យប៉ះពាល់ដល់គោលដៅជាគុណភាពផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការដំឡើងបង្គោលភ្លើងត្រូវបានដាក់ពិន្ទុដោយក្រុមអធិការកិច្ចថាពេញចិត្ត។

៣. ដោយសារតែបង្គោលភ្លើង ដែលបានដំឡើងមានចំនួនតិចជាងការគ្រោងទុក ទើបថវិកាមិនត្រូវបានចំណាយទាំងអស់នោះទេ។

៤. ជាសរុប លទ្ធផលគឺល្អ ហើយប្រសិនបើមិនមានបញ្ហាអាកាសធាតុទេ នោះគោលដៅទាំងអស់ប្រហែលជាអាចសម្រេចបានទាន់ពេលវេលាកំណត់។

*អនុសាសន៍÷*

ការលើកកម្ពស់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺជាចំណុចអាទិភាពគោលនយោបាយដែលមានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការដំឡើងភ្លើងបំភ្លឺផ្លូវនៅក្នុងភូមិ គឺស្របជាមួយនឹងគោលបំណងគោលនយោបាយ ពីព្រោះវារួមចំណែកដល់ការទប់ស្កាត់បទល្មើស ក៏ដូចជាសុវត្ថិភាពចរាចរណ៍ ផ្លូវគោក និងសុវត្ថិភាពអ្នកថ្មើរជើង។ ជាអនុសាសន៍ ការប្រើប្រាស់ថវិកាសម្រាប់សម្រេចលទ្ធផលក្នុងឆ្នាំនេះ គួរតែបន្តអនុវត្ត និងគួរធ្វើការកែលម្អ ដោយរំពឹងថានឹងបង្កើនថវិកាបន្ថែមទៀតនៅក្នុងឆ្នាំថវិកាបន្ទាប់។

✓ *ទី២- សូចនាករសមិទ្ធកម្មគន្លឹះលទ្ធផលក្នុងឆ្នាំសម្រាប់ចង្កោមសកម្មភាព*

សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាស់វែងលទ្ធផលក្នុងឆ្នាំ (Output)នៃចង្កោមសកម្មភាព គឺការតាមដានអំពីវឌ្ឍនភាពនៃការអនុវត្ត (សំដៅដល់សេវាត្រូវបានផ្តល់តាមការគ្រោងទុក)។

❖ *សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់សកម្មភាព*

សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់សកម្មភាពមានចំនួន ០២(ពីរ) គឺ÷ ការវាស់វែងវឌ្ឍនភាពជារូបវន្ត និងជាហិរញ្ញវត្ថុ។ ការវាស់វែងសូចនាករសមិទ្ធកម្មទាំងពីរនេះ គឺត្រូវផ្អែកលើរបាយការណ៍ប្រចាំខែ និងការវិភាគលើការប្រែប្រួល ដូចមានបង្ហាញក្នុងតារាងទី១៣ខាងក្រោម។

*តារាងទី១៣- ឧទាហរណ៍ការវិភាគការប្រែប្រួលនៃវឌ្ឍនភាពរូបវន្តសម្រាប់សកម្មភាព*

| **កូដកម្មវិធី (១)** | **សេចក្តីពណ៌នាសកម្មភាព (២)** | **សូចនាករសកម្មភាព (៣)** | **គោលដៅ (៤)** | **សម្រេចជាក់ស្តែង (៥)** | **ការប្រែប្រួល (៤-៥) =(៦)** | **% ៦/៤= (៧)** |
|---|---|---|---|---|---|---|
| | សេវាប្រពល-វប្បកម្មកសិកម្ម | ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់កសិករ | ១៥០ | ៥០ | ១០០ | ៦៧% |

ការវិភាគការប្រែប្រួលប្រហាក់ប្រហែលគ្នានេះត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃវឌ្ឍនភាពហិរញ្ញវត្ថុដូចបានបង្ហាញក្នុងតារាងទី១៤ ខាងក្រោម។

*តារាងទី១៤÷ ឧទាហរណ៍ការវិភាគការប្រែប្រួលនៃវឌ្ឍនភាពហិរញ្ញវត្ថុសម្រាប់សកម្មភាព*

គិតជាលានរៀល

| **កូដកម្មវិធី (១)** | **សេចក្តីពណ៌នាសកម្មភាព (២)** | **សូចនាករសកម្មភាព (៣)** | **ចំនួនថវិកា (៤)** | **ថ្លៃចំណាយជាក់ស្តែង (៥)** | **ការប្រែប្រួល (៤-៥) = (៦)** | **% (៦/៤) = (៧)** |
|---|---|---|---|---|---|---|
| | សេវាប្រពល-វប្បកម្មកសិកម្ម | ចំនួនវគ្គបណ្តុះបណ្តាលសម្រាប់កសិករ | ២ ៥០០ | ៣ ០០០ | (៥០០) | (១២%) |

តារាងទី១៣ និង ១៤ ខាងលើនេះបង្ហាញថា សកម្មភាពស្តីពី *«ការរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់កសិករ»* ដោយបានកំណត់គោលដៅ និងលទ្ធផលជាក់ស្តែងនៃចំនួនសិក្ខាកាមត្រូវបណ្តុះបណ្តាល (តារាងទី១៣) និងថវិកាត្រូវចំណាយ (តារាងទី១៤)។ សកម្មភាពទាំងអស់ដែលត្រូវការជាចាំបាច់ដើម្បីអនុវត្ត ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ និងគណនាថ្លៃចំណាយឱ្យបានច្បាស់លាស់ បើមិនដូច្នោះទេ នឹងមានបញ្ហាប្រឈមថវិកាមិនគ្រប់គ្រាន់ ដូចបានបង្ហាញក្នុងតារាងទី១៤។

### ៣.៧ ជំហានទី៧- វិធីសាស្ត្រក្នុងការគណនាតម្រូវការចំណាយសម្រាប់កម្មវិធី

*(ជំហានទី៧ នេះផ្តល់គំនិត និងវិធីគណនាតម្រូវការ ដើម្បីបំពេញនៅក្នុងតារាងឧបសម្ព័ន្ធទី១.៤, ១.៥,១.៦, ១.៧ និង ១.៨ ដូចមានភ្ជាប់មកជាមួយ)*

ជំហានទី៦ស្តីពីការកំណត់ KPI និងជំហានទី៧ស្តីពីការគណនាតម្រូវការចំណាយ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ព្រោះថាសូចនាករអាចសម្រេចទៅបានអាស្រ័យលើកញ្ចប់ធនធានដែលមាន។ ជាទូទៅ រដ្ឋបាលរាជធានី ខេត្ត អាចជ្រើសរើសការគណនាតម្រូវការចំណាយមុនការកំណត់សូចនាករក៏បានដែរ។ ទោះជាយ៉ាងនេះក្តី គោលការណ៍ណែនាំនេះ មានគោលបំណងផ្សារភ្ជាប់ការកំណត់ KPI ទៅនឹងការគណនាតម្រូវការចំណាយ ដើម្បីងាយស្រួលក្នុងការកសាងកម្មវិធី ព្រោះថានៅពេលកសាងថវិកាកម្មវិធីយើងត្រូវពិនិត្យសារចុះសារឡើង ដើម្បីធ្វើយ៉ាងណាឱ្យការកសាងថវិកាតាមកម្មវិធីដែលបានកំណត់នោះអាចអនុវត្តបាននៅក្នុងកម្រិតថវិកាប្រចាំឆ្នាំ និងក្នុងកម្រិតនៃកំណើនថវិកាសម្រាប់រយៈពេល២ឆ្នាំបន្ទាប់។ ផ្នែកនេះ ផ្តល់ការណែនាំអំពីការគណនាតម្រូវការចំណាយ ដែលត្រូវការសម្រាប់អនុវត្តសកម្មភាពការងារត្រូវបានកំណត់។

*ក្នុងការគណនាតម្រូវការចំណាយ រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្អែកលើមូលដ្ឋានគណនាចំនួនពីរគឺ ទី១-ការគណនាតម្រូវការចំណាយដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា និងទី២-ការគណនាតម្រូវការចំណាយដោយផ្អែកតាមកម្មវិធី។*

ដើម្បីឱ្យកម្មវិធីមួយមានធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្ត និងអាចត្រួតពិនិត្យបានធៀបនឹងកម្មវិធីផ្សេងៗទៀតក្នុងរដ្ឋបាលតែមួយ តម្រូវឱ្យមានយន្តការសម្របសម្រួលមួយសម្រាប់កំណត់តម្រូវការចំណាយនៃកម្មវិធីទាំងនោះ។ ការធ្វើបែបនេះ នឹងជួយពង្រឹងការផ្សារភ្ជាប់តម្រូវការចំណាយថវិកាទៅនឹងលទ្ធផលសម្រេចបាន ព្រមទាំងអាចវាយតម្លៃពីប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់កម្មវិធី។

ជាទស្សនៈ ការចំណាយទាំងអស់ត្រូវវិភាជន៍ទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ធនធានមួយអាចប្រើសម្រាប់កម្មវិធីលើសពីមួយ ដែលយើងគួរបែងចែកទៅតាមភាគរយនៃការប្រើប្រាស់សម្រាប់កម្មវិធីនីមួយៗ។ **ឧទាហរណ៍÷** យានយន្តមួយត្រូវបានប្រើប្រាស់ ៧៥% សម្រាប់



តទៅរាជកិច្ចលេខ ២៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៦២ រថ.អប្រក.ប្រក

## ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ ០០៦២ រថ.អប្រក.លអ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួម លេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួម លេខ១២៨សហវ.ប្រកចុះថ្ងៃទី០៣ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពលនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួម លេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ខែ វិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយល្បាយប្រេងនិង



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំ ស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់លោកHWANGDANIEL CHUNGWO
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

**ប្រការ១.–.**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ CALTEX **ព្រះសីហនុ២** ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ របស់ **ក្រុមហ៊ុន ឈេហ្វរ៉ុន (ខេមបូឌា) លីមីធីត** (ម្ចាស់ស្ថានីយ)។

**ប្រការ២.–.**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.–.**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល។

**ប្រការ៤.–.**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរចចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល។

**ប្រការ៥.–.**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការ ជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍ មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាពនៃលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០០៦៧.រ៉ែ.អធផក.ពអ..........ចុះថ្ងៃទី.....06................ខែ...មីនា.....ឆ្នាំ២០២០...របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសធ្ងន់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០០៦៧.រ៉ែ.អធផក.ពអ.ចុះថ្ងៃទី......06......ខែ......មីនា......ឆ្នាំ២០២០...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣**.-.

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តព្រះសីហនុ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហ. ១១កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក.ព.ស. ២៥៦៣

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី

-សាលាខេត្តព្រះសីហនុ

-ដូចប្រការ១៣

-រាជកិច្ច

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៩៦៤ ប្រក

**ប្រកាស**
**ស្តីពី**
**ការចុះឈ្មោះក្នុងបញ្ជីសមាគម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ និងលិខិតលេខ០២ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់សមាគមអភិវឌ្ឍកសិកម្មជួយជនក្រីក្រ

**សម្រេច**

**ប្រការ ១ .-**

ត្រូវបានចុះឈ្មោះ **សមាគមអភិវឌ្ឍកសិកម្មជួយជនក្រីក្រ** ក្នុងបញ្ជីសមាគម នៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅភូមិអន្ទ្រេះ ផ្លូវជាតិលេខ៧៦A ឃុំអបួនលើ ស្រុកកោះញែក ខេត្តមណ្ឌលគិរី។

**ប្រការ ២ .-**

**សមាគមអភិវឌ្ឍកសិកម្មជួយជនក្រីក្រ** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣ .-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ.................ខែ.................ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី........ ខែ........ ឆ្នាំ២០២០
រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុន-ហុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី